# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៥ ខែសីហា លេខ ៨

ព.ស. ២៤៩៦ – គ.ស. ១៩៥៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង


| ផ្នែកសាសនា | | ទំព័រ |
|---|---|---|
| — លោកធម៌ ................ | ព្រះឧបាលិវង្ស ម៉ឺង- សែស ... | ៥៦៣ |
| — កឋិនកថា (តមក) ............ | ព្រះមហាឧត្តមវិជ្ជា កែ - អឿន ... | ៥៧២ |
| — មនុស្សខ្ពង់ខ្ពស់នឹងថោកទាប ...... | លោក ប៊ូ ប៉ូ ........... | ៥៧៧ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — អំពីដើមកំណើតសកករាជ ... ....... | លោក ប៊ូ — ប៉ូ ........... | ៥៨៦ |
| — ការបណ្ដុះនិស្ស័យ (តមក)........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង – ប៉ម ... | ៥៩៥ |
| — រឿងសាមកុក (តមក)........... | ឧកញ៉ា ទួ – កន ......... | ៥៩៩ |
| — រឿងអារ័ក្សថ្លែងរឿងខ្មៃប្រាំ (តមក)... | លោក ភ៉ាយ - ប៊ុក ......... | ៦០៤ |
| — រឿងបិញ្ចៀនទិព្យ (តមក)......... | អ្នកស្រីសារីយ៉ាន់ ......... | ៦១០ |
| — រឿងប៉ូលនឹងវីរ័ស៊ីនី (តមក) ....... | លោក ផេង - ជ្រីវ ......... | ៦១៤ |
| — សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ (បរិយាយពីដើមកំណើតមហោរព) .. | លោក ជាប- ពិន ......... | ៦២៩ |
| **កំណត់ទិនប្បវត្តិការណ៍** | | |
| — សុន្ទរកថាបណ្ឌិតម៉ាល៉ាលសេកេរៈថ្លែងក្នុង .. សមាជសាកលលើកទី ២ នៃពុទ្ធសាសនា | (តមក) ពុទ្ធសាសនបណ្ឌិត្យ ... | ៦៣១ |
| — ពិធីស្រោចទឹកព្រះសង្ឃ ៣ អង្គ ... .. | ព្រះអាចារ្យ ឈុយ—វ៉ន់ ...... | ៦៣៥ |


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៩២រ. ០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE RELIGIEUSE

| | | Pages |
|---|---|---|
| — Lokadharma .............. | *Brah Upâlivongs MENG-SES..* | 563 |
| — Kathinakatha (suite)........ | *Brah Maha KER-ŒUNE ....* | 572 |
| — La destinée des hommes ..... | *M. BOU-PO .........* | 577 |

### PARTIE LITTERAIRE

| | | |
|---|---|---|
| — De l'origine des Sakaraja . . | *M. BOU PO .........* | 586 |
| — Education morale (suite) . . | *Brah Maha PEUNG-PAM . . .* | 595 |
| — Histoire de SAMBOK (suite) .. | *Oknha NOU-KAN ........* | 599 |
| — Les vingt cinq récits du Mauvais Génie (suite) ........... | *M. RAY-BUC ..........* | 604 |
| — La bague magique (suite).... | *Mme SARIS- YANN..........* | 610 |
| — Paul et Virginie (suite) ...... | *M. PHÉNG-CHRIEU ......* | 614 |
| — Activité de la Commission des Mœurs et Coutumes (Origine des théâtres) ............. | *M. CHAP-PIN ............* | 619 |

### NOTES ET CHRONIQUES

| | | |
|---|---|---|
| — Discours du Dr. MALALASEKERA au 2e Congrès Mondial Bouddhique (suite) ......... | *INSTITUT BOUDDHIQUE . . .* | 631 |
| — Cérémonie d'investiture . . . | *Brah Achar CHHUY-VON . .* | 635 |

Prix d'abonnement annuel comprenant 12 numéros : 192$00

# លោកធម៌

## ព្រះឧបាលិវង្ស ម៉ុង-សែស វត្តមហាមន្ត្រី ភ្នំពេញ

ទេសនាផាក់វិទ្យុប្រទេសកម្ពុជា កាលពីថ្ងៃ ១៤ រោច ខែផល្គុន ឆ្នាំជូតសំរិទ្ធិស័ក

ព.ស. ២៤៩១ (២៨-៣-៤៩)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង)

*" សូមនមស្ការចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយសេចក្ដីគោរព)" ។*

*អាត្មាភាពសូមសំដែងធម៌ផ្សាយទៅតាមវិទ្យុកម្ពុជា តាមសមគួរដល់វេលា ។*

*សូមសំដែងអំពីលោកធម៌តាមទំនងដែលមានក្នុងលោកធម្មសូត្រគម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត ព្រះសុត្តន្តបិដក ។* លោកធម្ម: *ប្រែថា "ធម៌របស់លោក" ។* លោក- *ស័ព្ទក្នុងទីនេះ ប្រែថា "*សត្វ*" ដែលគេធ្លាប់និយាយថា "*សត្វលោក*" ។ លោកធម៌តែងវិលទៅតាមប្រជាប់តាមលោក ចំណែកលោកក៏វិលទៅតាមប្រជាប់តាមលោកធម៌ដែរ; សត្វលោកចៀសមិនផុតរត់មិនរួចអំពីលោកធម៌ឡើយ, លោកធម៌តែងកើតមានដល់ពួកសត្វទាំងអស់ សូម្បីតែព្រះពុទ្ធជាម្ចាស់ក៏នៅមានលោកធម៌មកប៉ះត្រូវព្រះអង្គដែរ, តែព្រះអង្គមិនកគ្រេកញាប់ញ័រដោយលោកធម៌នោះឡើយ ។*

លោកធម៌នោះមាន ៨ ប្រការ គឺ

១ — លាភ: ការបាននូវវត្ថុមានចីវរមាសប្រាក់ជាដើម,

២ — អលាភ: ការមិនបាននូវវត្ថុមានចីវរមាសប្រាក់ជាដើម.

៣ — យស: យសសក្តិ បរិវារសម្បត្តិអំណាចឥស្សរភាព,

៤ — អយស: គ្មានយសសក្តិគ្មានបរិវារសម្បត្តិ គ្មានអំណាច គ្មានឥស្សរភាព,

៥ — និន្ទា ពាក្យតិះដៀលបន្តុះបង្អាប់,

៦ — បសំសា ពាក្យសរសើរលើកបញ្ជោរ ដំកុំដំកើង,

៧ — សុខ: សេចក្តីសុខកាយសប្បាយចិត្ត,

៨ — ទុក្ខ: សេចក្តីទុក្ខកាយលំបាកចិត្ត,

រួមជា ៨ ប្រការ ។

បណ្តាលោកធម៌ទាំងនោះ លោកធម៌ ៤ ប្រការ គឺលាភ ១ យស ១ សេចក្តីសរសើរ ១ សេចក្តីសុខ ១ ទាំង ៤ នេះតែងនាំឲ្យកើតសេចក្តីសោមនស្សសេចក្តីត្រេកអររីករាយ ភ្លើតភ្លើនជាធម្មតា បណ្តាលឲ្យកើតសេចក្តីស្រវឹងវង្វេង កើតមានឆ្មើងឆ្មៃព្រហើនមើលងាយគេពល់គ្នាថាមិនស្មើនឹងខ្លួនក៏មាន; បណ្តាលឲ្យកើតអាកប្បកិរិយា ដេកដើរឈរអង្គុយមិនសមរម្យដល់ក្មេកអ្នកទាំងពួងក៏មាន ។ បុគ្គលជាសប្បុរសពុំគួរបណ្តែត

បណ្ដោយចិត្តឲ្យកក្រើកញាប់ញ័រគឺត្រេកអរហួសហេតុ ដោយលាភយស សេចក្ដីសរសើរ នឹងសេចក្ដីសុខនេះឡើយ; គួរលៃលកប្រើចិត្តឲ្យសមល្មមទើបល្អ ។

លោកធម៌ ៤ ប្រការៈទៀត គឺ អលាភ ១ អយសៈ ១ និន្ទា ១ សេចក្ដីទុក្ខ ១ តែងនាំឲ្យកើតទោមនស្សសេចក្ដីខឹងអាក់អន់ចិត្តតូចចិត្តឈឺចិត្ត ស្ងិតស្ងប់ជប់ស្រពោនក្រៀមក្រស់ថ្ងុសមុខ នាំឲ្យគេស្គាល់ថាជាមនុស្សមិនសប្បាយចិត្ត ។ សាធុជនមិនគួរបណ្ដែតបណ្ដោយចិត្តឲ្យរន្ធត់រំភើបរញ្ជួយគឺតូចចិត្តហួសហេតុ ដោយលោកធម៌ទាំង ៤ នេះឡើយ គួរទប់ទល់ចិត្តឲ្យនឹងនួនល្អទើបគួរ ។

ចិត្តរបស់បុគ្គលណាដែលលោកធម៌ទាំង ៨ នេះពាល់ត្រូវហើយគ្របសង្កត់ហើយ តែងកក្រើកញាប់ញ័ររំភើប គឺត្រេកអរខ្លាំងនឹងខឹងខ្លាំង, ចិត្តរបស់បុគ្គលនោះមិនមែនជាមង្គលឡើយ, បើចិត្តមិនកក្រើកមិនញាប់ញ័រមិនរំភើបដោយលោកធម៌ទាំង ៨ នេះទេ ទើបជាមង្គលដ៏ឧត្ដម ។ ឯព្រះខីណាស្រពទាំងឡាយ លោកមិនកក្រើកដោយលោកធម៌នោះឡើយ ។

ន័យមួយទៀត លាភជាសក្ការៈដែលគេត្រូវប្រាថ្នាគ្រប់គ្នាក្នុងលោក លើកលែងតែព្រះខីណាស្រពនឹងព្រះអនាគាមិបុគ្គលចេញ; តែលាភនោះបើប្រកបដោយធម៌ ក៏ជាការគាប់ប្រសើរក្នុងលោក, បើមិនប្រកប

ដោយធម៌ទេ ជនជាសប្បុរសមិនគួរប្រាថ្នាឡើយ ។ លាភនោះបើកើតឡើងដល់បណ្ឌិត ច្រើនមានប្រយោជន៍ទៅដល់ជនច្រើនគ្នា, បើកើតឡើងដល់បុគ្គលពាលមិនសូវមានប្រយោជន៍ប៉ុន្មានទេ ជួនកាលក៏ក្លាយទៅជាថ្នាំពិសបំពុលបុគ្គលពាលនោះឲ្យស្លាប់វិនាសវិញក៏មាន ។

អលាភៈ ជាសភាវៈដែលគេមិនត្រូវប្រាថ្នាក្នុងលោកនេះ តែគង់មានបុគ្គលខ្លះត្រូវការដែរ ដូចយោគីបុគ្គលខ្លះដែលមានសេចក្ដីនឿយណាយអោកក្នុងសង្សារទុក្ខ លះបង់លាភសក្ការៈ លះបង់ពួកគណៈចៀសចេញទៅនៅទីស្ងប់ស្ងាត់ ធ្វើសមណធម៌ដោយមានបំណងយករូបាវចរកុសល អរូបាវចរកុសល និងលោកុត្តរកុសល ។

យសៈ ជាសភាវៈដែលគេត្រូវប្រាថ្នាដោយច្រើនក្នុងលោកនេះ ប្រហែលគ្នានឹងលាភដែរ ។

អយសៈ ជាសភាវៈដែលគេមិនត្រូវប្រាថ្នាដោយច្រើនក្នុងលោកនេះ ប្រហែលគ្នានឹងអលាភៈដែរ ។

និន្ទា ពាក្យតិះដៀលតែងកើតមានដល់ព្រះអាទិត្យ ព្រះចន្ទ ដី ទឹក ភ្លើង ខ្យល់ជាដើម ។ ចំណែកសត្វវិញ្ញាណកវត្ថុ សូម្បីតែព្រះពុទ្ធក៏គង់មានដែរ, សមដូចបាលីពុទ្ធភាសិតថា នត្ថិ លោកេ អនិន្ទិតោ "ក្នុងលោកនេះគ្មានអ្នកណាមួយដែលគេមិននិន្ទានោះទេ" តែពាក្យនិន្ទារបស់បុគ្គលពាលកំឡៅយកជាការមិនកើត យកជាប្រមាណមិនបាន, បុគ្គល

ពាលជួនកាលនិន្ទាទៅលើបុគ្គលដែលគួរសរសើរ ជួនកាលសរសើរបុគ្គលដែលគួរទឹងនិន្ទាទៅវិញ, បើបណ្ឌិតប្រកបដោយអំពើសុចរិត ទឹងបញ្ញាជ្រាលជ្រៅ ប្រសិនបើពោលពាក្យនិន្ទាមនុស្សណា ទើបយកជាការបាន យកជាប្រមាណកើត ៗ

បសំសា ពាក្យសរសើរមានដំណើរសេចក្ដីផ្ទុយគ្នាទឹងពាក្យនិន្ទានោះ ៗ សេចក្ដីសរសើរនេះមានកម្លាំងអាចច្រានមនុស្សខ្វះឲ្យដួលដេកផ្កាប់ផ្ការទៅលើគំនរភ្លើងធំ ទៅលើចំរូងបន្លា ទៅលើទោសទុក្ខគុកច្រវាក់ ជួនកាលក៏ត្រូវទោសអស់ ១ ជីវិតក៏មាន ជួនកាលក៏ដល់នូវសេចក្ដីស្លាប់វិនាសក៏មាន ៗ អ្នកមានប្រាជ្ញាមិនគួរជោរជន់ដោយសេចក្ដីសរសើរពេកឡើយ ៗ

សេចក្ដីសុខក្នុងលោកនេះមានតិចតួចស្ដួចស្ដើង ជាងសេចក្ដីទុក្ខ ៗ មានច្រើនជាងសេចក្ដីសុខហួសប្រមាណ, មនុស្សទាំងឡាយតែងស្វះស្វែងរកសេចក្ដីសុខគ្រប់គ្នា ប៉ុន្តែនៅតែមិនសូវបានសេចក្ដីសុខទៀត ៗ

បើនិយាយដោយសង្ខេបថា សេចក្ដីសុខរបស់គ្រហស្ថមាន ៤ យ៉ាង គឺសុខកើតអំពីមានទ្រព្យសម្បត្តិ ១ សុខកើតអំពីចាយទ្រព្យបរិភោគ ១ សុខកើតអំពីគ្មានចំពាក់បំណុលគេ ១ សុខកើតអំពីប្រកបការងារដែលឥតទោស ១, សេចក្ដីសុខដទៃក្រៅពីនេះក៏មាន តែមិនបាច់យកមកសំដែងឲ្យវែងឆ្ងាយពេកទេ ៗ

កងមនុស្សលោកនេះ សេចក្ដីសុខមានហើយទើបកើតសេចក្ដីចំរើនជាខាងក្រោយ ដូចជាអរុណមានមុនទើបព្រះអាទិត្យមានក្រោយ, បើយើងចង់បានសេចក្ដីចំរើនកងផែនទាំងមូល ត្រូវរកសេចក្ដីសុខជាមុន ។

ប្រៀបដូចជាត្រកូល ១ ចិញ្ចឹមក្របីមួយហ្វូង, ប៉ុណងអ្នកម្ចាស់ក្របីនោះចង់ឲ្យហ្វូងក្របីនោះចំរើនលូតលាស់កើតកូនកើតចៅច្រើនឡើង នឹងមានប្រយោជន៍ដល់ខ្លួនដោយសារក្របីទាំងនោះ ទើបអ្នកម្ចាស់ក្របីសួរបណ្ឌិតបុរសម្នាក់ថា: បពិត្របុរសជាបណ្ឌិត! ខ្ញុំមានក្របី ១ ហ្វូង ខ្ញុំចង់ឲ្យក្របីនោះចំរើនកើតកូនកើតចៅកាន់តែច្រើនឡើង តើធ្វើឧបាយដូចម្ដេច? សូមអ្នកប្រាប់ឧបាយខ្ញុំផង ។

បណ្ឌិតបុរសនិយាយប្រាប់ឧបាយថា: បើអ្នកត្រូវការចង់ឲ្យហ្វូងក្របីរបស់អ្នកចំរើន ត្រូវអ្នករកសេចក្ដីសុខឲ្យដល់ហ្វូងក្របីនោះជាមុន ត្រូវអ្នកស្គាល់ហេតុដែលនាំឲ្យក្របីវិនាសមាន ៤ យ៉ាង គឺ ១– គ្មានស្មៅគ្មានទឹកឲ្យវាស៊ីផឹក, ២– មានជម្ងឺកាត់បុះកងហ្វូងក្របី, ៣– មានចោរលួចប្លន់យកទៅ. ៤– ក្របីទាំងនោះបៀតបៀនគ្នា ដេញគ្នារត់ចាក់ទៅវាត់គ្នាស្លាប់វិនាសទៅ ។ ហេតុទាំង ៤ នេះហៅថា: គ្មានសេចក្ដីសុខ ត្រូវអ្នកដេញក្របីទាំងនោះទៅកាន់ទីមានទឹកជ្រៅស្មៅវែង ឲ្យវាផឹកវាដេកវាស៊ីតាមចំនើងចិត្តវា, ត្រូវអ្នករកពេទ្យហ្មថ្នាំសង្កូវបំរុងចាំថែរក្សាការពាររោគកុំឲ្យកើតមានកងហ្វូងក្របីនោះ, ត្រូវប្រុងប្រយ័ត្នកុំឲ្យចោរលួចប្លន់

យកក្របីបាន, ត្រូវអ្នកប្រុងប្រយ័ត្នកុំឲ្យក្របីវាបៀតបៀនគ្នាដេញគ្នារត់បាត់ទៅ ឬវៃគ្នាស្លាប់វិនាសទៅ វេលាយប់ដេញក្របីចូលក្រោល មើលក្របីណាដែលឈ្នះគេ ហើយកាចផង ត្រូវយកពួរទាក់ចងឲ្យជាប់ កុំឲ្យវាបៀតបៀនគ្នា, អ្នកធ្វើយ៉ាងនេះឈ្មោះថាធ្វើសេចក្ដីសុខដល់ហ្វូងក្របី បើបានសុខហើយសេចក្ដីចំរើនមុខជានឹងមានពុំខានឡើយ ៗ

អ្នកម្ចាស់ក្របីបានស្ដាប់ពាក្យបណ្ឌិតបុរសពន្យល់ហើយ ក៏ធ្វើតាមដោយសព្វគ្រប់ ក៏បានសេចក្ដីចំរើនដោយលំដាប់ឥតមានវិនាសឡើយ ៗ

សាធុពេ បពិត្រសប្បុរសទាំងឡាយ ! ជាតិមនុស្សក្នុងលោកនេះ ដែលបានសេចក្ដីចំរើន មកអំពីបានសេចក្ដីសុខជាមុន ទើបបានសេចក្ដីចំរើនជាខាងក្រោយ ដូចហ្វូងក្របីនោះឯង ៗ

ក្នុងមនុស្សលោកនេះ មានសេចក្ដីទុក្ខច្រើនប្រការពេកណាស់ គួរតែអាធុញទ្រាំនឹងទុក្ខ. ការស្វែងរកអាហារចិញ្ចឹមជីវិតដោយធ្វើស្រែចំការក៏មិនងាយនឹងបរិភោគឆ្អែត, ជួនកាលមានភ្លៀងតិចពេកក៏ធ្វើមិនបាន មានភ្លៀងច្រើនពេកក៏ធ្វើមិនកើតដែរ; អ្នកដែលរកចិញ្ចឹមជីវិតដោយស៊ីឈ្នួលគេក៏មិនងាយនឹងគ្រប់គ្រាន់ ៗ អ្នកជំនួញជួញប្រែជួនកាលក៏ខាតជួនកាលក៏ចំណេញ, រួមទាំងអស់ទៅហៅថាអាហារបរិយេដ្ឋិទុក្ខគឺលំបាកកើតអំពីស្វែងរកអាហារ ៗ

ជម្ងឺជំកាត់គ្រប់ជំពូក មានកញ្ជ្រិលអុតស្វាយអុតធំ រោគពិស អាសន្នរោគជាដើមជាសេចក្ដីទុក្ខ ១ ដែរ ៗ

ចោរកំណាចរុករានចោរក្រាស់ បំបាត់ប្រវ័ញ្ចន៍លួចឆក់ដណ្តើម គម្រាមប្លន់រាយកាប់ចាក់សម្លាប់យកទ្រព្យសម្បត្តិដុតចាំងផ្ទះផងក៏មាន នេះជាសេចក្តីទុក្ខភ័យ ១ យ៉ាងធំក្នុងមនុស្សលោក ។

វិវាទ ការទាស់ទែងគ្នា ឈ្លោះប្រកែកគ្នា ប្រណាំងប្រជែងដណ្តើមយកឈ្នះតែរៀងខ្លួនមិនព្រមចុះចាញ់ទេណា ហេតុដល់ទៅប្រហារគ្នាដោយគ្រឿងប្រហារមានដំបងជាដើមក៏ជាសេចក្តីទុក្ខ ១ ដែរ ។

សេចក្តីទុក្ខដូចបានរៀបរាប់មកមានដូច្នេះជាដើមនេះ មានអារម្មណ៍ទាំង ៥ ជាហេតុ ឬបណ្តាលមកអំពីអារម្មណ៍ទាំង ៥ ដែលហៅថាបញ្ច-ពិធកាមគុណគឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលជាទីប្រាថ្នា ជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់សត្វ, ពួកសត្វតែងស្រវាំងវង្វេងងងុលងប់ជ្រុលជ្រប់ផ្តេកផ្តួលចិត្តទៅក្នុងអារម្មណ៍ទាំង ៥ នោះខ្លាំងពេកណាស់ បើពួកសត្វរាប់អានប្រើប្រាស់អារម្មណ៍ទាំង ៥ នោះខ្លាំងណាស់ទៅ សេចក្តីទុក្ខក៏ខ្លាំងណាស់ដែរ បើពួកសត្វបន្ថយការរាប់អានប្រើប្រាស់អារម្មណ៍ទាំង ៥ នោះឲ្យថយតិចចុះមក សេចក្តីទុក្ខក៏ថយតិចចុះមកដែរ ។

ម្យ៉ាងទៀត ពួកសត្វដែលជាប់ជំពាក់សល់រំលំដោយកងទុក្ខ ឬផុតអំពីទុក្ខក៏ព្រោះចិត្តតែម្យ៉ាងជាហេតុ; ចិត្តណាដែលកាមគុណទាំង ៥ មានអំណាចនាំទៅបាន ទាញមកបាន ចាប់បង្ខិលបាន, ចិត្តនោះឯងជាហេតុឲ្យជាប់នៅក្នុងកងទុក្ខ; ចិត្តណាដែលកាមគុណទាំង ៥ នាំទៅមិន

បាន ទាញមកមិនរួច ចាប់បង្ខិលមិនបានទេ ចិត្តនោះឯងជាហេតុឲ្យផុតអំពីទុក្ខ ។

លោកអ្នកប្រាជ្ញពោលមកដោយសេចក្តីសង្ខេបបំប្រួញឲ្យខ្លី ហើយឲ្យបានសេចក្តីវែងឆ្ងាយថា: ទុក្ខំ តេភូមិកំ វដ្តំ តណ្ហា សមុទយោ ភវេ "វដ្ដៈមានភូមិ ៣ ហៅថាទុក្ខសច្ច តណ្ហាហៅថា សមុទយសច្ច" ។ វដ្តៈ ។ ប្រែថា ធម្មជាតិជាទីប្រព្រឹត្តទៅ ឬវិលទៅនៃកម្មនឹងកម្មវិបាក ។ ភូមិ ៣ នោះ គឺកាមាវចរភូមិ ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ ។ តណ្ហាជាហេតុឲ្យកើតកងទុក្ខ ហៅថាសមុទ័យ, តណ្ហាក៏គឺលោក ១ ជាមូលនៃបាបអកុសលទាំងឡាយ ៗ តែងឲ្យផលជាទុក្ខ ។

អាត្មាភាពសំដែងលោកធម៌ទាំង ៨ ប្រការមកនេះ ក៏សូមបញ្ចប់ទេសនាត្រឹមតែប៉ុណ្ណេះ ។

សូមថ្វាយព្រះរាជកុសល ចំពោះព្រះករុណាជាអម្ចាស់ជីវិតព្រះចៅក្រុងកម្ពុជាធិបតី ព្រមទាំងព្រះរាជវង្សានុវង្ស ! សូមជូនកុសលដល់អស់លោក-អ្នករាជការគ្រប់ដំណែងកងកម្ពុជរដ្ឋ នឹងពួកសប្បុរសដែលបានស្តាប់ធម៌នេះគ្រប់ខ្មែរដែលមានវិទ្យុរស័ព្ទ សូមឲ្យបានសម្រេចឥដ្ឋមនុញ្ញផលដូចប្រាថ្នាកុំបីឃ្លាតឡើយ !

ឯវំ សង្ខេបេន សមត្តា ធម៌ទេសនាក៏ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

របៀបទេសនាបុច្ឆា - វិសជ្ជនា

## ព្រះមហាឧត្តមវិជ្ជា កែ-អឿន (វីរិយប្បញ្ញោ)

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង

## ព្រះទេពសត្ថា ស្មួរ-ហាយ ពិនិត្យកែសម្រួល

(តមក)

– ភន្តេ មហាថេរ: បពិត្រព្រះមហាថេរដ៏ចំរើន! តាមគម្ពីរវិនយាលង្ការដីកា បង្គាប់ថា ញត្តិទុតិយកម្មវាចាយ ទាតព្វំ "ត្រូវសង្ឃប្រគល់ឲ្យដោយញត្តិទុតិយកម្មវាចា" ។ ឯញត្តិទុតិយកម្មវាចា ជាវាចាប្រគល់សំពត់កឋិនតាមពុទ្ធានុញ្ញាតក្នុងគម្ពីរមហាវគ្គ ដែលភិក្ខុសង្ឃតែងសូត្ររៀងរាល់កាលតែកឋិនមាននោះឯង សូមមានប្រោស ។

១៦– ម្នាលអនុគ្តេរ! ខ្ញុំយល់ហើយ, ចុះបើសង្ឃប្រគល់សំពត់កឋិនឲ្យយ៉ាងនេះហើយ ត្រូវឲ្យភិក្ខុអ្នកក្រាលប្រតិបត្តិដូចម្តេច? ។

– ភន្តេ ថេរ: បពិត្រព្រះមហាថេរដ៏ចំរើន! តាមគម្ពីរបរិវារៈបង្គាប់ថា តេន កឋិនត្ថារកេន ភិក្ខុនា តទហេវ ធោវិត្វា វិមជ្ជិត្វា វិចារេត្វា ឆិន្ទិត្វា សិព្វេត្វា រជិត្វា កប្បំ កត្វា កឋិនំ អត្ថរិតព្វំ "ត្រូវឲ្យភិក្ខុអ្នកក្រាលកឋិននោះ បោក គក់ ប្រមាច់ វាស់កាត់ ដេរ ជ្រលក់ ធ្វើកប្បពិន្ទុឲ្យហើយស្រេចក្នុងថ្ងៃនោះ. ហើយក្រាលកឋិន

ទៅចុះ"; តែធ្វើឲ្យកន្លងថ្ងៃនោះទៅ ក្រាលកឋិនមិនកើតឡើយ ។ បពិត្រព្រះថេរៈ! ខ្ញុំព្រះករុណាវិសជ្ជនាមកបានសេចក្តីប៉ុណ្ណេះ សូមក្រាប ។

១៧– សាធុ សាធុ អនុរុទ្ធៈ ម្នាលអនុរុទ្ធ! ប្រស្នាដែលលោកម្ចាស់ឆ្លើយមកនេះ ត្រូវពិតហើយ; ចុះបើចីវរកឋិននោះទាយកជាសាមីទានគេធ្វើបរិកម្មសម្រេចជា ស្បង់-ចីពរ-សង្ឃាដី រួចស្រេចស្រាប់មកហើយ, គេវេរប្រគេនដល់សង្ឃតែម្តង តើសង្ឃត្រូវប្រតិបត្តិដូចម្តេច? លោកម្ចាស់ ។

– បពិត្រព្រះមហាថេរ! បើតាមគន្ថគម្ពីរកង្ខាវិតរណីអដ្ឋកថានិងគន្ថគម្ពីរវជិរពុទ្ធដីកា ពោលសរសើរថា កតបុព្វករណមេវ ឧប្បជ្ជតិ សុគ្គរមេវ បើចីវរដែលទាយកធ្វើបុព្វករណៈរួចហើយ កើតឡើងដល់សង្ឃជាការប្រពៃណាស់ហើយ ដោយហេតុគ្រហស្ថជាអ្នកឈ្លាសវៃក្នុងការកាត់ដេរជ្រលក់ចីវរ. ត្រូវសង្ឃទទួលហើយប្រគល់ឲ្យទៅភិក្ខុអ្នកក្រាលដោយកម្មវាចាចុះ មិនបាច់ធ្វើបរិកម្មទៀតទេ ប្រៀបដូចកុលបុត្រដែលមានកេសាកោរស្រេចហើយត្រូវបំបួសឲ្យទៅចុះ ឯភិក្ខុអ្នកក្រាលកឋិននោះសោតត្រូវអធិដ្ឋានក្រាលក្នុងមណ្ឌលសីមានោះ រួចហើយត្រូវញុំាងសង្ឃឲ្យអនុមោទនាតែម្តងទៅ ព្រោះមិនមានកិច្ចនឹងត្រូវធ្វើបុព្វ-ករណៈ ដែលគេធ្វើត្រឹមត្រូវទាំងកាត់ដេរជ្រលក់រួចមកហើយនោះម្តងទៀតទេ, កាលបើសង្ឃប្រគល់ចីវរកឋិនដែលសម្រេចស្រាប់មកឲ្យយ៉ាង

នេះហើយ បើភិក្ខុអ្នកក្រាលកឋិន ត្រូវការក្រាលដោយសង្ឃាដី ត្រូវបច្ចុទ្ធរ៍ដកសង្ឃាដីចាស់ចេញ អធិដ្ឋានសង្ឃាដីថ្មីឡើង រួចហើយត្រូវបញ្ចេញវចីភេទក្រាលចុះ, បើត្រូវការក្រាលដោយស្បង់ឬចីពរ ក៏ត្រូវធ្វើដូចគ្នានឹងសង្ឃាដីចុះ; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាវិសជ្ជនាមក បានសេចក្តីយ៉ាងនេះ សូមទានជ្រាប ។

១៨ – សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមក ក៏ឃើញថាត្រឹមត្រូវពិតប្រាកដដូចនោះមែនពិតហើយ ។ សាធុរៅ បពិត្រសាធុសប្បុរសទាំងឡាយ! លោកអ្នកគប្បីសន្និដ្ឋានចូលចិត្តជឿឲ្យស៊ប់ក្នុងគម្ពីរទាំងពីរ ដែលលោកម្ចាស់អនុត្តរបានពោលអាងហើយនោះចុះ ឥតមានខុសឃ្លៀងឃ្លាតឡើយ ។ ឥតោ បរំ ដទៃអំពីនេះទៅ ខ្ញុំនឹងលើកយកអានិសង្សខាងទាយក អ្នកធ្វើចីវរទានមកសួរលោកម្ចាស់វិញទៀត ។ អើលោកម្ចាស់ ចំណែកទាយកអ្នកធ្វើចីវរទានតើនឹងបានអានិសង្សយ៉ាងណាទៅ? សូមលោកម្ចាស់និមន្តលើកយករឿងនិទានណាមួយ ដែលមានសំដែងក្នុងគម្ពីរមកសំដែងកែខៃសេចក្តីដើម្បីអស់លោកអ្នកពុទ្ធបរិស័ទ បានជ្រាបច្បាស់ផងមើល ។

ភន្តេ មហាថេរៈ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន! បុគ្គលដែលប្រកបដោយសទ្ធា បានធ្វើចីវរទាន រមែងបានអានិសង្សប្រយោជន៍នឹងសេចក្តីសុខជាច្រើន ដូចមានវត្ថុនិទានសំដែងថា អតីតេ ពារាណសិយំ

ឯកោ កុដុម្ពិកោ ក្នុងកាលដ៏កន្លងទៅហើយ មានកុដុម្ពិកម្នាក់នៅក្នុងនគរពារាណសី មានកាលថ្ងៃមួយ ត្រេចដើរទៅក្នុងព្រៃ បានជួបនឹងព្រះបច្ចេកពុទ្ធមួយព្រះអង្គកំពុងដេរចីវរ ដែលខ្វះសំពត់មិនទាន់គ្រប់គ្រាន់ត្រង់អនុវាតបណ្តោយ កុដុម្ពិកនោះក៏មានចិត្តជ្រះថ្លា ហើយយកសំពត់សម្រាប់បង្ករបស់ខ្លួនប្រគេនទៅព្រះបច្ចេកពុទ្ធ ។ ដោយអានុភាពនៃបុញ្ញកម្មនេះ បុរសនោះក៏បានទៅកើតក្នុងស្ថានតាវត្តិង្សទេវលោកបានសោយទិព្វសម្បត្តិជាយូរអង្វែង លុះច្យុតអំពីទេវលោកនោះមកក៏បានមកកើតក្នុងត្រកូលអាមាត្យនៅក្នុងទីចម្ងាយ ១ យោជន៍អំពីនគរពារាណសី ។ បុរសនោះមានវ័យវឌ្ឍនាការចំរើនធំឡើង ។ មានកាលមួយថ្ងៃជាថ្ងៃលេងនក្ខត្តឫក្ស បុរសនោះនិយាយនឹងមាតារបស់ខ្លួនថា "បពិត្រអ្នកម៉ែ! ចូរអ្នកឲ្យសំពត់ ១ មកខ្ញុំ ខ្ញុំនឹងទៅលេងនក្ខត្តឫក្សនឹងគេ" ។ មាតានោះក៏ឲ្យសំពត់ស្អាត ១ ទៅ ។ បុរសនោះនិយាយថា "សំពត់នេះមានសាច់គ្រោតគ្រាតណាស់ ខ្ញុំមិនយកទេ" ។ មាតាក៏ឲ្យសំពត់ដទៃទៀត បុរសនោះក៏មិនព្រមយកសំពត់នោះទៀត បាននិយាយនឹងមាតាថា "បើអ្នកម្តាយរកសំពត់សាច់ម៉ដ្ឋឲ្យខ្ញុំមិនបានទេ ខ្ញុំនឹងទៅស្វែងរកសំពត់គួរជាទីគាប់ចិត្តឲ្យបាន" ។ មាតានិយាយថា 'ម្នាលកូន! មាតាមិនស្អប់កូនទេ សព្វថ្ងៃនេះម្តាយចង់ឲ្យកូនឯងបានសោយរាជ្យក្នុងនគរពារាណសីនេះផង' ។ បុរសនោះក៏ថ្វាយបង្គំលាមាតាដើរចេញទៅ ។

ហេតុតែកុសលកសិអំពីបុព្វជាតិត្រូវអំណោយផល បុរសនោះដើរចូលទៅកាន់នគរពារាណសី ហើយចូលទៅដេកទទូរលើផែនថ្មមង្គលសិលាក្នុងសួនឧទ្យាន ។ កាលនោះជាថ្ងៃព្រះរាជាក្នុងនគរពារាណសីទ្រង់សោយព្រះទិវង្គតទៅបាន ៧ ថ្ងៃហើយ ។ ពួកជនមានអាមាត្យជាដើម នាំគ្នាធ្វើសរីរកិច្ចនៃព្រះរាជាជាស្រេច រួចប្រឹក្សាគ្នាថា "ឥឡូវព្រះរាជាមានតែព្រះរាជធីតា ៦ ព្រះរាជបុត្រមិនមានឡើយ ធម្មតាស្រុកនគរបើឥតមានស្តេច នឹងមិនបានស្ថិតស្ថេរយូរឡើយ នឹងត្រូវវិនាសជាប្រាកដ" ហើយក៏រៀបចំបុស្សរថ ទឹមសេះសិន្ធព ៤ មានពណ៌សម្បុរដូចផ្កាកុម្ទ ហើយយករាជកកុធភណ្ឌទាំង ៥ ប្រការដាក់លើរថ រួចលែងបុស្សរថទៅ ។ បុស្សរថនោះក៏ចេញទៅតាមទិសខាងកើត ហើយចូលទៅកាន់សួនឧទ្យាន ប្រទក្សិណកុមារដែលដេកទទូរក្នុងទីនោះហើយឈប់នៅស្ងៀមធ្វើអាការហាក់ដូចជាប្រុងប្រៀបខ្លួនឲ្យកុមារឡើងជិះ ។ បុរោហិតក៏បើកដាយសំពត់ឡើងមើលឃើញផ្ទៃបាតៈជើងសព្វគ្រប់ ហើយទាយថា "បុរសនេះគួរនឹងសោយរាជ្យបាន" ហើយក៏ប្រគំតូរ្យតន្ត្រីអស់ការៈ ៣ ជង់ ។ លំដាប់នោះកុមារក្បាលខ្លួនបើកក្អែកឡើងសួរថា "អ្នកទាំងឡាយនាំគ្នាមករកអ្វី?" ។ ជនទាំងឡាយតបថា 'បពិត្រព្រះសម្មតិទេព ! ឥឡូវរាជសម្បត្តិធ្លាក់លើព្រះអង្គហើយ" ។

(មានត)

# មនុស្សខ្ពង់ខ្ពស់និងថោកទាប

ចូឡកម្មវិភង្គសូត្រ ក្នុងសុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក
ឃុនបណ្ណាទីរក្យ ប៊ូ - ប៉ូ ក្រសួងពុទ្ធសាសនបណ្ឌិត្យ ជាអ្នកប្រែ(១)

---

គ្រានោះ សុភមាណពជាបុត្ររបស់តោទេយ្យព្រាហ្មណ៍បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលសួរប្រស្នាថា បពិត្រព្រះគោតមដ៏ចំរើន! អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យ ដែលនាំឲ្យពួកមនុស្សកាលកើតមកជាមនុស្សមានសេចក្តីថោកទាបនិងខ្ពង់ខ្ពស់ប្រាកដឡើង ព្រោះថា មនុស្សទាំងឡាយមានអាយុខ្លី មានអាយុវែង មានអាពាធច្រើន មានអាពាធតិច មានសម្បុរអាក្រក់ មានសម្បុរល្អ មានសក្តិតូច មានសក្តិធំ មានភោគសម្ប័ទតិច មានភោគសម្ប័ទច្រើន មានត្រកូលទាប មានត្រកូលខ្ពស់ មានប្រាជ្ញាតិច មានប្រាជ្ញាច្រើន? ។

ព្រះ – ម្នាលមាណព! សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរលឹក កម្មតែងចែកសត្វទាំងឡាយឲ្យថោកទាបនិងឲ្យខ្ពង់ខ្ពស់ ។

សុភមាណព - ខ្ញុំព្រះអង្គមិនយល់សេចក្តីពិស្តាររបស់ភាសិតសង្ខេបនេះទេ សូមព្រះអង្គសំដែងចែកសេចក្តីពិស្តារឲ្យទាន ។

---

១ ប្រែប្រួតកាត់បោលសេចក្តីខ្លះត្រង់ដែលមានសេចក្តីផ្ទួន ៗ ។

ព្រះ- ម្នាលមាណព ! បើដូច្នោះ អ្នកចូរយកចិត្តទុកដាក់ចាំស្តាប់ឲ្យប្រពៃចុះ តថាគតនឹងសំដែង ។

## ១- ហេតុឲ្យមានអាយុខ្លី

ម្នាលមាណព ! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ប្រព្រឹត្តអាក្រក់ មានដៃប្រឡាក់ឈាម តាំងនៅក្នុងការបៀតបៀន និងការសម្លាប់ មិនអាណិតពួកសត្វ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើមិនទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានអាយុខ្លី ។

## ២- ហេតុឲ្យមានអាយុវែង

ម្នាលមាណព ! មួយទៀត ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត មានដម្បងនឹងសស្ត្រាដាក់ចុះហើយ ជាអ្នកមានសេចក្តីអៀនខ្មាស មានសេចក្តីអាណិតអាសូរ អនុគ្រោះដោយប្រយោជន៍ ក្នុងពួកសត្វទាំងអស់ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងមានអាយុវែង ។

## ៣ - ហេតុឲ្យមានអាពាធច្រើន

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆានប្រេតវិស័យ អសុរកាយ នរក ប្រសិនបើមិនទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានអាពាធច្រើន ។

## ៤ - ហេតុឲ្យមានអាពាធតិច

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានអាពាធតិច ។

## ៥ - ហេតុឲ្យមានសម្បុរអាក្រក់

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីក្រោធ ច្រើនទៅដោយសេចក្តីចង្អៀតចង្អល់ចិត្ត គ្រាន់តែគេស្តីថាបន្តិច

បន្តុបកំភ្លាំង ខឹង ព្យាបាទ តបត សំដែងសេចក្តីក្រោធ ប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើមិនបានទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានសម្បុរអាក្រក់ ។

## ៦ _ ហេតុឲ្យមានសេចក្តីជ្រះថ្លា (សម្បុរល្អ)

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនក្រោធ មិនច្រើនទៅដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេស្តីថាច្រើន ក៏មិនរកាំង មិនក្រោធ មិនព្យាបាទ មិនតបត មិនសំដែងនូវសេចក្តីក្រោធ ប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា (សម្បុរល្អ) ។

## ៧ _ ហេតុឲ្យមានសក្តិតូច

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកច្រណែន តែងច្រណែន ប្រទូស្ត ក្នុងលាភសក្ការៈ និងសេចក្តីគោរព ការរាប់

អាន ការថ្វាយបង្គំ ការបូជា របស់បុគ្គលទាំងឡាយដទៃ បង់ទុកនូវសេចក្តីប្រណែន ៗ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើមិនបានទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានសក្តិតូច ។

## ៨_ហេតុឲ្យមានសក្តិធំ

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះក្នុងលោកនេះ ជាអ្នកមិនប្រណែន រមែងមិនប្រណែន មិនប្រទូស្ត ក្នុងលាភសក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ ការបូជា របស់បុគ្គលទាំងឡាយដទៃ មិនបង់ទុកនូវសេចក្តីប្រណែន ៗ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានសក្តិធំ ។

## ៩_ហេតុឲ្យមានភោគសម្បត្តិតិច

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានឲ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ទីដេក ទីអាស្រ័យ ប្រទីប ដល់សមណៈឬព្រាហ្មណ៍ ៗ ព្រោះអំពើដែល

ខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើមិនបានទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានភោគសម្បទតិច ៗ

## ១០_ ហេតុឱ្យមានភោគសម្បទច្រើន

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកឱ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ទីអាស្រ័យ ប្រទីប ដល់សមណព្រាហ្មណ៍ ៗ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានភោគសម្បទច្រើន ៗ

## ១១_ ហេតុឱ្យមានត្រកូលថោកទាប

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នករឹងត្អឹងមើលងាយ មិនសំពះបុគ្គលដែលគួរសំពះ មិនក្រោកទទួលបុគ្គលដែលគួរក្រោកទទួល មិនឱ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ មិនឱ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ មិនធ្វើសក្ការៈដល់បុគ្គលដែលគួរដល់សក្ការៈ មិនធ្វើសេចក្តីគោរពដល់បុគ្គលដែលគួរធ្វើសេចក្តីគោរព មិនរាប់អានដល់

បុគ្គលដែលគួរកោប់អាន មិនបូជាដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយនរក ប្រសិនបើមិនទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានត្រកូលថោកទាប ។

## ១២ – ហេតុឲ្យមានត្រកូលខ្ពង់ខ្ពស់

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនរឹងត្អឹង មិនមើលងាយ សំពះបុគ្គលដែលគួរសំពះ ក្រោកទទួលបុគ្គលដែលគួរក្រោកទទួល ឲ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ ឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ ធ្វើសក្ការៈដល់បុគ្គលដែលគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរពដល់បុគ្គលដែលគួរគោរព កោប់អានបុគ្គលដែលគួរកោប់អាន បូជាបុគ្គលដែលគួរបូជា ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានត្រកូលខ្ពង់ខ្ពស់ ។

## ១៣ – ហេតុឲ្យគ្មានប្រាជ្ញា

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈព្រាហ្មណ៍ហើយមិនបានសាកសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន! អ្វីជា

កុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីជាទោស ដើម្បីជាទុក្ខ អស់កាលដ៏យូរ មួយយ៉ាងទៀត អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ អស់កាលដ៏យូរ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើមិនបានទៅកើតក្នុងកំណើតទាំង ៤ នេះទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកគ្មានប្រាជ្ញា ។

## ១៤— ហេតុឲ្យមានប្រាជ្ញាច្រើន

ម្នាលមាណព! ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះចូលទៅជិតសមណៈឬព្រាហ្មណ៍ហើយសាកសួរថា បពិត្រលោកដ៏ចំរើន! អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីជាទោស ដើម្បីជាទុក្ខ អស់កាលដ៏យូរ មួយយ៉ាងទៀត អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ អស់កាលដ៏យូរ ។ ព្រោះអំពើដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើមិនបានទៅកើតក្នុងស្ថានសួគ៌ទេ បើបានត្រឡប់មកជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានប្រាជ្ញាច្រើន ។

ម្នាលមាណព! ព្រោះហេតុថា សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានអាយុខ្លី រមែងនាំឲ្យមានអាយុខ្លី ។ល។ សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានប្រាជ្ញាច្រើន រមែងនាំឲ្យមានប្រាជ្ញាច្រើន ។

កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ សុភមាណព តោទេយ្យបុត្តបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន! ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន! ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន! ធម៌ដែលព្រះអង្គសំដែងហើយដោយអនេកបរិយាយយ៉ាងនេះ (ក៏ច្បាស់ណាស់) ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬក៏ប្រាប់ផ្លូវដល់មនុស្សវង្វេង ពុំនោះសោត ដូចជាគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹតដោយគិតថា ឲ្យពួកមនុស្សដែលមានភ្នែកក៏មើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះតទៅ ។

ចប់

នត្ថិ កម្មសមំ ពលំ

គ្មានកំឡាំងអ្វីស្មើនឹងកំឡាំងកម្ម

ជ ។.

# ឃុនបណ្ណារក្ស ប៊ុ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

## បរិយាយដើម

មនុស្សក្នុងសាកលលោកគ្រប់ជាតិគ្រប់សាសន៍ សុទ្ធសឹងតែមានកិច្ចការត្រូវធ្វើទាំងអស់គ្នា គ្មានអ្នកណានៅស្ងៀមឡើយ ព្រោះធម្មតាលោកបង្គាប់ឲ្យធ្វើ ៗ ឯកិច្ចការរបស់អ្នកស្រុកទាំងអស់នោះ ដែលនឹងចំរើនកើនឡើងតាមលំដាប់ទៅបាន ដោយសារតែមានពេល-ម៉ោង-ថ្ងៃ-ខែ-ឆ្នាំជាគ្រឿងកត់សំគាល់ ដូចមានពេលព្រឹក-ល្ងាច-ថ្ងៃ-យប់ជាដើម ៗ សូម្បីការសរសេរសំបុត្រស្នាមទៅមករកគ្នា ក៏ត្រូវចុះថ្ងៃ-ខែ-ឆ្នាំខានមិនបានដែរ ៗ ហេតុនេះ ការចេះចាំថ្ងៃ-ខែ-ឆ្នាំ មានប្រយោជន៍ជាយ៉ាងច្រើន ៗ បើប្រទេសណាមិនប្រើពេល-ម៉ោង-ថ្ងៃ-ខែ-ឆ្នាំទេ ប្រទេសនោះនឹងធ្វើការអ្វីៗឥតកម្រិត ឥតរបប ឥតក្របខ័ណ្ឌ ឥតរបៀប មិនរៀបរយ នាំឲ្យការងារទាំងនោះប្របូកប្របល់រសេមរសាម គឺថាធ្វើការព្រឹកជាល្ងាចៗ ជាព្រឹក, ខែនេះជាខែនោះ, ឆ្នាំនេះជាឆ្នាំនោះ ចំណាំបានច្បាស់ប្រាកដតែរដូវថា រដូវភ្លៀង, រដូវរាំង, រដូវទឹកឡើង, រដូវទឹកស្រក នឹងរដូវស្លឹកឈើជ្រុះជាដើម ៗ ពុំនោះសោត គេទុកជាកន្ទូវមនុស្សពួកនោះ ថាជាមនុស្សល្ងង់ខ្លៅ

គួយ៉ាងដូចជាមិលក្ខៈ គឺមនុស្សព្រៃ, មនុស្សព្នង ដែលអាស្រ័យនៅក្នុងកោះតូចតាច ឆ្ងាយដាច់ស្រយាលពីគេ ឬអាស្រ័យជ្រកៈនៅក្នុងព្រៃជ្រៅជាយកៀនកោះ ជាបន្ទោះប្រទេសរបស់គេ, មនុស្សចំពួកនេះប្រើតែគំនូសជំនួសអក្សរ តាំងពីកើតទល់គ្នានឹងស្លាប់ទៅវិញ ពុំដែលបានស្គាល់នូវរសជាតិនៃអារ្យធម៌នឹងគេសោះ ។ ហេតុដូច្នោះ បានជាលោកអ្នកប្រាជ្ញជាន់ដើមកំណត់ឲ្យប្រើពេល-ម៉ោង-ថ្ងៃ-ខែ-ឆ្នាំ ហៅថា "សករាជ" ជាគ្រឿងចំណាំ ។

ឯសករាជដែលគេនិយមប្រើក្នុងប្រទេសខ្មែរយើងសព្វថ្ងៃនេះ មាន ៤ យ៉ាង គឺ ១- ពុទ្ធសករាជ, ២- គ្រិស្តសករាជ, ៣- មហាសករាជ, ៤- ចុល្លសករាជ ។ ឯសករាជទាំង ៤ យ៉ាងនេះគេរៀបរៀងតាមលំដាប់ដែលកើតមុន កើតក្រោយ ដូចតទៅនេះ គឺ

១- ពុទ្ធសករាជ កើតមុនសករាជទាំង ៣;

២- គ្រិស្តសករាជ កើតក្រោយ ព.ស. ៥៤៣ ឆ្នាំ;

៣- មហាសករាជ -ដ- -ដ- ៦២១ -ដ-;

៤- ចុល្លសករាជ -ដ- -ដ- ១.១៨១ -ដ- ។

## អធិប្បាយអំពីសករាជទាំង ៤ តាមលំដាប់គ្នា

ពុទ្ធសករាជ.— ក្នុងវចនានុក្រមខ្មែរ ភាគទី ១ ទំព័រ ៦២៩ ប្រាប់ថា ពុទ្ធសករាជ គេកំណត់រាប់ចំនួនថ្ងៃខែឆ្នាំ តាំងពីក្រោយ

ថ្ងៃដែលព្រះពុទ្ធអង្គ ទ្រង់ចូលបរិនិព្វានទៅបានមួយថ្ងៃរៀងមក ។ ព្រះសក្យមុនីគោតម ទ្រង់ចូលបរិនិព្វាននៅថ្ងៃអង្គារ ១៥ កើត ខែពិសាខ ឆ្នាំម្សាញ់,រាប់ពីត្រឹមថ្ងៃ ១ រោចខែពិសាខឆ្នាំនោះមក ជាពុទ្ធសករាជ ។

ការរាប់ពុទ្ធសករាជ ជាការកំណត់ថ្ងៃខែឆ្នាំរបស់ពួកពុទ្ធសាសនិកជន សម្រាប់ប្រើខាងទេសនា ដែលហៅថា "បកសករាជ" ។ របៀបនេះ រាប់យកចំណែកខាងរនោចខែមួយមុនមកប៉ះរួមនឹងខ្នើតខែបន្ទាប់នោះជា ១ ខែ គឺត្រូវរាប់ពីថ្ងៃ ១ រោចខែពិសាខមកដល់ថ្ងៃ ១៥ កើតខែជេស្ឋ ជា ១ ខែ ។ល។ ពីថ្ងៃ ១ រោចខែចេត្រ មកដល់ថ្ងៃ ១៥ កើតខែពិសាខ ជា ១ ខែ (ពេញជា ១ ឆ្នាំ) រាប់យ៉ាងនេះរៀងរាល់ឆ្នាំ, បើរាប់ពីលើមកដល់ត្រឹមណា ត្រូវទុកថ្ងៃខែឆ្នាំនោះជាបច្ចុប្បន្នកាល មិនទាន់ពេញថាជាសករាជដែលកន្លងទៅហើយទេ, ដូចជាកាលពីក្នុងថ្ងៃ ១៥ រោចខែស្រាពណ៍ ឆ្នាំមមី បន្ទាប់ឆ្នាំពុទ្ធបរិនិព្វាន ត្រូវរាប់ថា ពុទ្ធសករាជកន្លងទៅហើយបាន ១ ឆ្នាំ ៣ ខែ ១៤ ថ្ងៃ (កន្លងទៅហើយបានប៉ុន្មាន ត្រូវថាត្រឹមប៉ុណ្ណោះ). តែបើប្រើខាងការសរសេរសំបុត្រចុតហ្មាយ កត់ត្រាបុះក្នុងគម្ពីរក្បួនច្បាប់ទាំងពួង ឬនិយាយស្តីប្រាប់គ្នាតាមធម្មតានោះ ត្រូវរាប់បញ្ចូលចំនួនសករាជយកត្រឹមឆ្នាំមមីដែលចូលក្នុងរវាងឆ្នាំគំរប់ ២ នុ៎ះឯងថា ពុទ្ធសករាជ ២ ឆ្នាំ ឬពុទ្ធសករាជ ២, បើប្រើអក្សរសង្ខេបត្រូវសរសេរថា ព.ស. ២ ។

ពុទ្ធសករាជនេះ ចាប់ផ្តើមកើតមានឡើងជាដំបូងនៅក្នុងប្រទេសឥណ្ឌា ដោយពួកពុទ្ធបរិស័ទមានព្រះសង្ឃជាដើមក្នុងប្រទេសនោះ

កំណត់ឲ្យប្រើឡើង ចាប់រាប់តាំងពីក្រោយថ្ងៃដែលព្រះពុទ្ធអង្គទ្រង់ចូលបរិនិព្វានទៅបាន ១ ថ្ងៃ គឺកំណត់រាប់តាំងពីត្រឹមថ្ងៃពុទ្ធ ១ រោចខែពិសាខ. ឆ្នាំម្សាញ់នោះមក ឲ្យឈ្មោះថាជាពុទ្ធសករាជ ដោយមានថ្ងៃបរិនិព្វាននៃព្រះពុទ្ធជាគោលចារិក, ហើយតមកក្នុងប្រទេសនានា ដែលជាប្រទេសកាន់ព្រះពុទ្ធសាសនា ដូចប្រទេសខ្មែរជាដើម ក៏និយមប្រើតៗគ្នាមករហូតដល់សព្វថ្ងៃនេះ ។

ឯប្រទេសឥណ្ឌា កាលពីសម័យមុន ដែលពុំទាន់មានពុទ្ធសករាជនៅឡើយ គេនិយមប្រើបុរាណសករាជ គឺសករាជខាងសាសនាព្រាហ្មណ៍ជាច្រើនពាន់ឆ្នាំមកហើយ ។ លុះដល់មានពុទ្ធសករាជ ប្រទេសឥណ្ឌា ក៏ចាប់ប្រើពុទ្ធសករាជជាប់ឡើង ។ ក្នុងសម័យបច្ចុប្បន្ននេះប្រទេសឥណ្ឌាឈប់ប្រើពុទ្ធសករាជទៅហើយ, តែគេប្រើសករាជអ្វីយើងមិនបាច់និយាយ ។

គ្រិស្តសករាជ.— ក្នុងវចនានុក្រមខ្មែរ ភាគទី ២ ទំព័រ ៧៩៧ ប្រាប់ថា គ្រិស្តសករាជនេះ គេបង្កើតឡើងតាមនាមនិងពង្សាវតារនៃសាស្តាម្នាក់ឈ្មោះ ហ្សេហ្ស៊ូ ឬហ្សេហ្ស៊ូ-គ្រិស្ត (Jésus ou Jésus-Christ) ជាអ្នកបង្កើតលទ្ធិ ឬសាសនាមួយ ហៅថាសាសនាគ្រិស្ត (Religion Chretienne) ក្នុងកាលសតវត្សរ៍ទី ៦ នៃពុទ្ធសករាជ (ព.ស. ៥៤៣) ។ ពិតមែនតែព្រះហ្សេហ្ស៊ូ-គ្រិស្ត ទទួលមរណភាពក្នុង

ព. ស. ៤៧៦ ក្នុងអាយុគំរប់ ៣៣ ឆ្នាំ តែគេបានតាំងសករាជនោះគិតពីថ្ងៃដែលសាស្តានេះកើត គឺក្នុង ព. ស. ៥៤៣ ហៅថា គ្រិស្តសករាជ សរសេរអក្សរសង្ខេបថា គ. ស. គឺសករាជដែលគេនិយមប្រើក្នុងប្រទេសអឺរុបនិងប្រទេសអាស៊ីជាច្រើន ក្នុងសម័យសព្វថ្ងៃនេះ ។

មហាសករាជ.— ក្នុងវចនានុក្រមខ្មែរ ភាគទី ១ ទំព័រ ៧៤៤ និងភាគទី ២ ទំព័រ ១០៨១ ប្រាប់ថា ស័ក ប្រែថា "កាល, សម័យ យុគ ...," រាជ ប្រែថា "ស្ដេច" ។ ការរាប់ថ្ងៃខែឆ្នាំឬការរាប់ត្រឹមតែឆ្នាំ តាមកាលកំណត់ដែលតាំងទុកពីមួយរៀងមកដោយមានបុគ្គលអស្ចារ្យ ឬដោយមានហេតុអស្ចារ្យណាមួយ ដែលពួកជនានុជនអ្នកគោរពត្រូវកត់ត្រាទុកមិនឲ្យបាត់, ត្រូវប្រើក្នុងសំបុត្រចុតហ្មាយជាដើម បង្កើនមួយលេខរៀងរាល់ឆ្នាំ ហៅថា "សករាជ" ។ នេះកើតឡើងអំពីជនមួយពួកហៅថា ពួកតាត នៅក្នុងតំបន់មួយខាងទិសពាយ័ព្យប្រទេសឥណ្ឌា ក្នុងកាល ព. ស. ៦២១ ឆ្នាំ ។ កាលជនពួកនេះមានជ័យជំនះក្នុងការលុកលុយចូលមកវាតអំណាចក្នុងប្រទេសឥណ្ឌាប៉ែកខាងលិច បានតាំងក្សត្រជាតិរបស់ខ្លួនមានព្រះនាមថា សក: ឬសាលិវាហន:, ហើយក៏ចាប់ផ្ដើមរាប់ឆ្នាំតាំងពីមួយរៀងមក, ហៅរបៀបការរាប់ឆ្នាំនោះថា "ស័កឬសករាជ" ដែលចំណេរតមក ហៅថា "មហាសករាជ" ប្រែថា "ស័ករាជធំ" ។ នេះកើតមុនចុល្លសករាជ ៥៦០ ឆ្នាំ, ជាប់មានប្រើក្នុងប្រទេសខ្មែរ

ឃើញតាំងពីពាក់កណ្តាលសតវត្សរ៍ទី ១០ នៃពុទ្ធសករាជ (ព. ស. ៩២១) រហូតមកដល់សព្វថ្ងៃនេះ ប្រើអក្សរសង្ខេបថា ម. ស.[១] ។

មហាសករាជ ប្រាកដជាកើតឡើងក្នុងប្រទេសឥណ្ឌាជាដំបូងក្នុង ព. ស. ៦២១ ឆ្នាំ អំពីជនពួកមួយ ដូចមានរៀបរាប់ខាងលើនេះ, មិនមែនកើតឡើងជាដំបូងនៅប្រទេសខ្មែរដោយព្រះកេតុមាលាតាំងឡើងក្នុង ព. ស. ៦២១ នោះទេ ។

ក្នុងព្រះរាជពង្សាវតារខ្មែរ ភាគទី ២ ថា ព្រះកេតុមាលាកាលស្តេចឡើងគ្រងរាជសម្បត្តិក្នុង ព. ស. ៦២១ ឆ្នាំមែន ជាមួយនឹងឆ្នាំដែលប្រទេសឥណ្ឌាបង្កើតឲ្យប្រើមហាសករាជ, ប៉ុន្តែទ្រង់ពុំទាន់បញ្ញត្តឲ្យប្រើមហាសករាជ ក្នុងឆ្នាំនោះនៅឡើយទេ ។ លុះដល់មក ព. ស. ៦២៣ ឆ្នាំ ព្រះកេតុមាលាទ្រង់បានទទួលឥន្ទ្រាភិសេកជាថ្មី ក៏តាំងជាមហាសករាជជាប់មក ។ (ត្រង់នេះហើយប្រហែលជា ព្រះកេតុមាលាបញ្ញត្តឲ្យប្រើមហាសករាជ តាមប្រទេសឥណ្ឌា ហើយគេនិយមថាព្រះកេតុមាលាផ្តើមបង្កើតមហាសករាជ ជាប្រថមនៅប្រទេសខ្មែរ) ។

**ចុល្លសករាជ.—** ក្នុងវចនានុក្រមខ្មែរ ភាគទី ១ ទំព័រ ១៥២

---

១ ច្បាប់មគ្គុទ្ទេសក៍នគរ ភាគទី ១ ទំព័រ ២ ថា លុះដល់មកចុងសតវត្សរ៍ទី៩ និងខាងដើមសតវត្សរ៍ទី ១០ នៃពុទ្ធសករាជ ទើបមានព្រាហ្មណ៍មកពីប្រទេសឥណ្ឌៀឈ្មោះកោណ្ឌញ្ញៈ មកសោយរាជ្យនៅប្រទេសហ្វូណន បានរៀបចំទំនៀមប្រពៃណីប្រទេសហ្វូណនឲ្យប្រព្រឹត្តទៅតាមលទ្ធិប្រទេសឥណ្ឌៀឡើង ។

ប្រាប់ថា ចុល្លសករាជ ប្រែថា "សករាជតូច" ។ នេះចាប់ផ្តើមតាំងឡើង នៅថ្ងៃចន្ទ ១២ កើតខែចេត្រ ឆ្នាំកុរឯកស័ក ព.ស. ១.១៨១ ។

ក្នុងវចនានុក្រមខ្មែរ ភាគទី ២ ទំព័រ ១.០៨១ ប្រាប់ថា ក្នុងព្រះរាជពង្សាវតារខ្មែរថា ព្រះបាទសម្តេចព្រះអរិជ្ជពលពាហនោ (ព្រះកេតុមាលា) បានតាំងមហាសករាជ១ ក្នុងកាល ព.ស. ៦២១ ។ ព្រះបាទសម្តេចសិទ្ធពអមរិន្ទបរមព្រហ្មកិល (ពញាក្រែក) បានតាំងចុល្លសករាជ ១ ក្នុងកាល ព.ស. ១.១៨១ ក្នុងឆ្នាំដែលទ្រង់បានសោយរាជ្យនៅនគរធំ ។

ក្នុងច្បាប់រាជពង្សាវតារក្រុងកម្ពុជាធិបតីខ្សែ២ ប្រាប់ថា កាល ព.ស. ១ ១៨៣, ម.ស. ៥៦១ ឆ្នាំកុរឯកស័ក ត្រូវនឹង គ.ស. ៦៣៩ ព្រះបាទសម្តេចព្រះបទុមសុរិយាវង្ស ស្តេចតាំងឲ្យមានជាចុល្លសករាជឡើង រាប់ ១ រៀងមក ។

ក្នុងច្បាប់ព្រះរាជពង្សាវតារក្រុងកម្ពុជា ដែលលោកទេពពិទូរ ឈឹម-ក្រសេម បានរួបរួមឡើងជាថ្មីថា ក្សត្រមនព្រះនាមសង្ឃរាជ ជាក្សត្រទី ១៩ ក្នុងវង្សសមុទ្របុទ្ធ ទ្រង់តាំងចុល្លសករាជឡើង ។

**សេចក្តីវិនិច្ឆ័យ:** ចុល្លសករាជនេះ បានជេញជោល់គេទៅយល់ឃើញថា មាន ២ ផ្លូវ គឺយល់ថា ក្សត្រមនបានតាំងឡើងជាដំបូងក្នុងប្រទេសមននោះក៏បាន ។ បើនឹងយល់ថា ក្សត្រខ្មែរ បានតាំងចុល្លសករាជឡើងជាដំបូងក្នុងប្រទេសខ្មែរក៏បានដែរ ។ ប៉ុន្តែ ត្រូវយល់

ថា មានតែព្រះបាទជយវរ្ម័នទី ១ [១] ទ្រង់បានតាំងចុល្លសករាជឡើងជាដំបូង ក្នុងឆ្នាំដែលទ្រង់បានសោយរាជ្យ ក្នុង ព.ស. ១.១៨១ នេះ ឃើញគួរជាង ព្រោះក្សត្រអង្គនេះសោយរាជ្យនៅនគរវត្ត ហើយបានតាំងប្រើចុល្លសករាជដរាបមក (ដែលថា យ៉ាងនេះដោយអាងច្បាប់ព្រះរាជ-ពង្សាវតារដែលលោកទេពពិទូរ ឈឹម-ក្រសេម រួបរួមជាន់ក្រោយ) ។

**ការប្រើសករាជ.—** ក្នុងប្រទេសកម្ពុជាប្រើសករាជ ៤ យ៉ាង គឺ ពុទ្ធសករាជ, មហាសករាជ, ចុល្លសករាជ និងគ្រិស្តសករាជ ។

ឯពុទ្ធសករាជ និងមហាសករាជ ប្រាកដជាមានដើមកំណើតកើតឡើងក្នុងប្រទេសឥណ្ឌា ដោយសារជនជាតិឥណ្ឌាដែលជាអ្នកកាន់លទ្ធិសាសនាដូចគ្នានឹងខ្មែរផង ដោយសារអារ្យធម៌ឥណ្ឌាសាយភាយចូលមកក្នុងប្រទេសខ្មែរយើងផង បានជាខ្មែរយើងនិយមប្រើពុទ្ធសករាជនិងមហាសករាជខ្លះ តាមអារ្យធម៌ឥណ្ឌាតាំងពីសម័យនោះមក ។

តែកាលពីសម័យនគរភ្នំជាដំបូង រហូតមកទល់គ្នានឹងសម័យនគរធំ ជនជាតិខ្មែរពុំទាន់បានប្រើពុទ្ធសករាជនិងចុល្លសករាជជាផ្លូវការនៅឡើយទេ ប្រើតែមហាសករាជមួយយ៉ាងប៉ុណ្ណោះ លុះមកដល់ខាងចុងសម័យនគរធំ ទើបមានប្រើចុល្លសករាជផងជាផ្លូវការ រួមជាមួយពុទ្ធសករាជ និងមហាសករាជ រឿងនេះដឹងបានដោយសារមានសិលាចារិកជាភស្តុតាង ។

---

១ ច្បាប់មគ្គុទ្ទេសក៍នគរភាគទី ១ ទំព័រ ៣ ថា ព្រះបាទជយវរ្ម័នទី ១ ទ្រង់សោយរាជ្យក្នុងសតវត្សរ៍ទី ១៣ នៃពុទ្ធសករាជ (ព.ស. ១.២០៣ - ១.២១០) ។

ចំណែកគ្រិស្តសាសនាជ ចាប់ផ្ដើមប្រើក្នុងប្រទេសខ្មែរ តាំងពីរជ្ជកាលនៃព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះអង្គឌួង) គឺតាំងពី ព.ស. ២.៣៩១, គ.ស. ១.៨៤៧ រៀងមក ដោយសារប្រទេសបារាំងសែសនឹងប្រទេសកម្ពុជា មានការទាក់ទងគ្នាតាំងពីសម័យនោះមក ។

ការរៀបរៀងអត្ថបទសករាជដូចខាងលើនេះ ឃើញថាត្រឹមត្រូវល្មមទុកជាគតិទៅអនាគតបាន ដោយមានក្បួនគម្រោងជាកស្តុតាងគ្រប់សករាជ, ប៉ុន្តែបើពិនិត្យអំពីការប្រើសករាជនៅប្រទេសខ្មែរយើង ក្នុងសម័យបច្ចុប្បន្ននេះ ជាផ្លូវការក្តី ជាសាធារណៈក្តី ឃើញប្រើនតែប្រើគ្រិស្តសករាជពុំសូវមានប្រើពុទ្ធសករាជឡើយ ។

ហេតុនេះ ក្នុងសម័យនេះ គួរលើកយកពុទ្ធសករាជមកចុះប្រើជាផ្លូវការ នឹងប្រើជាសាធារណៈ ទុកជាសរណៈដល់ពុទ្ធសករាជ, នេះឃើញថាជាទីសមរម្យដល់ប្រទេសកាន់ពុទ្ធសាសនា ដូចជាប្រទេសថៃជាដើម ។

ចប់ ដោយសង្ខេប

# ការបណ្ដុះនិស្ស័យ

## ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

*អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង*

## ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

ចំពោះពួកញាតិ បើលោក-អ្នកទាបជាងគេដោយវ័យ សូម្បីលោក-អ្នកជាមនុស្សវិសេសជាងគេ ដោយដំរេះវិជ្ជាសក្ដិយស អំណាចវាសនានឹងទ្រព្យសម្បត្តិក៏ដោយ ក៏កុំវាយឫកចិត្តម៉ឹតប៉ើងម៉ើងតំកើងខ្លួនឡើយ គួរធ្វើការគោរពគុនលំទោនចំពោះញាតិដែលចាស់ជាង ហើយបើលោក-អ្នកជាបុគ្គលស្មើគ្នាដោយវ័យ ក៏គួរសំដែងសេចក្ដីរាប់អានគ្នាឲ្យសមវ័យសមជាន់ មិនមើលងាយគ្នាដោយហេតុគ្នាគ្មានវាសនា ឬសូម្បីលោក-អ្នកជាអ្នកធំ ក៏គួរសំដែងអធ្យាស្រ័យ មេត្តាករុណាប្រណីចំពោះញាតិអ្នកតូច ៗ ចំពោះពួកមិត្ត បើលោក-អ្នកធ្លាប់ស្និទ្ធស្នាលគ្នាមកយ៉ាងណា សូម្បីលោក-អ្នកបានសេចក្ដីចំរើនរុងរឿង ក៏កុំប្រែចិត្តឡើយ ចូររាប់អានគ្នាឲ្យស្និទ្ធស្នាលតាមប្រក្រតីដើម ៗ ចំណែកខាងពួកគណៈនឹងញាតិមិត្តវិញ បើបានទទួលសេចក្ដីគោរពរាប់អានយ៉ាងនេះហើយ ក៏គួរសំដែងសេចក្ដីស្រឡាញ់សេចក្ដីគោរពរាប់អានតបវិញ ដែលជាហេតុធ្វើសេចក្ដីសាមគ្គីព្រមព្រៀងគ្នាឲ្យជាប់លាប់មាំមួន ៗ

នេះជាបទគួរពេក :– “ ពូជ ពង្ស ប្រៀបដូចជាខសដែលមានរនើក ភ្លើង កាលដាក់បង្គរលើគ្នា ក៏ឆេះឡើងបានភ្លាម; សរសៃអំបោះ សូម្បីវែងឬខ្លី បើយកមកវេញផ្គួបបញ្ចូលគ្នាហើយ ក៏ជាប់ស្វិត អាចចងដំរីបាន; ព្រឹក្សជាតិដែលដុះឡើងនៅទីវាលទោលតែមួយ ទុកជាធំខ្ពស់មាំទាំមានឫសកែវមាំមួនយ៉ាងណាក៏ដោយ ក៏អាចត្រូវពាយុបោកបក់បំបាក់រំលើងឫសគល់ឲ្យបែកធ្លាយ ឲ្យរលើងទៅបានក្នុងខណៈមួយរំពេច តែពួកឈើដែលមានឫសមាំ ដុះឡើងជាមួយគ្នាជាពួកជាក្រុម អាស្រ័យការជួយទប់អំពីគ្នានឹងគ្នា ក៏អាចទប់តនឹងខ្យល់បាន ” ។ ដូច្នេះ អ្នកនៅតាមទំនើងម្នាក់ឯង សូម្បីសត្រូវតែម្នាក់ឯង ក៏អាចផ្ដាញ់ឲ្យចាញ់បានដូចជាខ្យល់ដែលរំលើងដើមឈើដែលដុះទោលតែម្នាក់ឯងបានដូច្នោះ ។ វង្សត្រកូលនឹងចំរើនរុងរឿងដូចឈូកដែលដុះនៅក្នុងស្រះបាន ក៏ព្រោះអាស្រ័យមនុស្សនៅក្នុងវង្សត្រកូលនោះមានសាមគ្គីព្រមព្រៀងគ្នា ទោះបីអ្នកមានឫទ្ធិអំណាច ក៏គង់ផ្ដាញ់អ្នកដែលរួមកំឡាំងគ្នាពុំបាន សូម្បីអ្នកនោះអន់កម្លាំងជាងក៏ដោយ ។ អ្នកមានបងប្អូនច្រើន ហើយមានសាមគ្គីព្រមព្រៀងគ្នា រមែងមានជំហររឹងប៉ឹង ដូចជាការដុះជាលរឹងប៉ឹងឡើងនៃគុម្ពឫស្សីដែលមានបន្លាដុះជុំវិញ ដែលនរណាក៏ដោយមិនងាយនឹងចូលទៅកាប់យកបានដូច្នោះ ។

កាយ វាចា ត្រូវលោក-អ្នកប្រព្រឹត្តឲ្យគួរដល់ឋានៈរបស់បុគ្គល ៗ គ្រឿងប្រដាប់សក់ មិនត្រូវយកទៅតុបតែងជើង ឬកងជើងមិនត្រូវយកមកតុបតែងលើសីសៈឡើយ ៗ កែវមណីមានដំឡៃច្រើន គួរយកទៅដាំលើផ្ទាំងមាស បើយកទៅដាំលើផ្ទាំងសំណក៏មិនសមនឹងដំឡៃរបស់វា កាលបើដូច្នោះ ក៏ជាកំហុសរបស់ជាងអ្នកធ្វើ, យកកញ្ចក់ទៅដាំនៅមកុដមាស · យកកែវមណីទៅដាំនៅកងជើង យ៉ាងនេះទឹងចាត់ថាជាទោសនៃមាសឬកែវមណីក៏មិនបាន គឺមនុស្សអ្នកប្រើនោះឯងមិនស្គាល់របៀបប្រើនេះយ៉ាងណា អ្នកមិនចេះដាក់ខ្លួនឲ្យត្រូវតាមឋានៈក៏ដូចគ្នា ៗ ខ្លួនជាអ្នកតូច ហ៊ានវាយបុកធ្វើជាអ្នកធំកប់ពពក ! ស្លៀកដណ្ដប់ហ៊ឺហាហួសឋានៈ នឹងហួសចំនួនរកបានរបស់ខ្លួន ប្រើមាសប្រាក់ថែបដូចជាអ្នករកបានច្រើនណាស់ ឃើញមិត្តភក្តិមានរថយន្តជិះ សូម្បីខ្លួនមិនមានប្រាក់កាស ក៏សុខចិត្តខ្ចីលុយគេទិញ ឬទិញជឿគេមកដើម្បីឲ្យពេញមុខពេញមាត់ស្មើនឹងមិត្តភក្តិ ដែលគេមានទ្រព្យច្រើនជាងខ្លួន ៗ បញ្ចេញសិល្បវិជ្ជាដែលខ្លួនមានបន្តិចបន្តួចមកគ្រប់សង្កាត់អ្នកដទៃ ខ្លួនជាអ្នករៀនបានទទួលអាហារូបត្ថម្ភ ឬបានលុយកាក់បន្តិចបន្តួចអំពីមាតាបិតា ហ៊ានស្លៀកពាក់ស៊ីចាយ ដើរលេងឲ្យហ៊ឹកហ៊ាក់ស្មើនឹងអ្នកធ្វើការដែលមានរបៀវត្សច្រើន ឱ! គួរឲ្យចង់សើចណាស់ ! នេះហៅពេញជាមនុស្សមិនចេះដាក់ខ្លួនឲ្យត្រូវនឹងឋានៈ ៗ

មនុស្សមិនចេះដាក់ខ្លួនឲ្យសមនឹងឋានៈ តែងប្រព្រឹត្តខ្ជីខ្ជានិងខុសក្បាត់យ៉ាងនេះ ។ មនុស្សបែបនេះមុខជាបានទទួលសេចក្ដីទោមនស្សតូចចិត្ត ព្រោះខុសបំណងប៉ងប្រាថ្នា ព្រមទាំងវិបត្តិវិនាសផ្សេងៗ ដែលកើតមកអំពីការប្រព្រឹត្តតាមបែបល្ងង់ខ្លៅរបស់ខ្លួនឯង ។ ព្រោះថាការដាក់ខ្លួនមិនត្រូវឬមិនសមគួរ ដូចយ៉ាងដាក់ខ្លួនទុកក្នុងឋានៈខ្ពស់ហួសសភាពពិតរបស់ខ្លួនរមែងក្លាយទៅជាការប្រព្រឹត្តរំលងស្រែកអឺតក្រអឺតទម្ពង់កើងខ្លួនចំពោះតែអ្នកដទៃ ។ ការប្រព្រឹត្តដូច្នោះ ក្រៅពីជាគ្រឿងធ្វើខ្លួនឯងឲ្យអាប់ឱនទឹកថោកទាបហើយ គង់ជាគ្រឿងទំលាយខ្លួនឲ្យវិនាសផងទៀត ។ ចំណែកការចេះទុកដាក់ខ្លួនឲ្យស្មើឲ្យសមគួរល្មមល្អមើល មិនខ្ពស់ពេក មិនទាបពេក រមែងជាគ្រឿងការពារអ្នកមានឋានៈខ្ពស់មិនឲ្យធ្លាក់ទៅទាប និងទំនុកបំរុងផងផ្ដើមលើកស្ទួយអ្នកមានឋានៈទាបឲ្យខ្ពស់ឡើងដោយលំដាប់ ចាត់ថា ជាកិត្តិយសដ៏ប្រសើរក្រៃលែង ។

ប្ដូរលោក - អ្នកដាក់ទឹកក្នុងត្រឡោក ហើយឈ្ងោកធ្ងុះមើលមុខខ្លួនឯងខ្លះផង តើជាយ៉ាងណាទៅ?

(មានត)

## កណ្ឌទី ១៧

### ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ចូឆូបានស្តាប់ដូច្នោះសើចហើយថា អ្នកនិយាយដូច្នេះយើងក៏ដឹងច្បាស់ហើយ តែនៅបារម្ភក្រែងថាយើងធ្វើការសង្គ្រាមគ្រានេះនឹងមិនដូចពាក្យថា ។ ស៊ុនហុកដំរាបចូឆូថា ដែលគុយកែនិយាយថាលោកនឹងមានជ័យជំនះអ៊ួនសៀវ ១០ ប្រការនោះ ខ្ញុំបាទយល់ឃើញត្រូវផង ព្រោះអ៊ួនសៀវមិនជាអ្នកចេះគិតក្រវែង សូម្បីបើមានទាហានច្រើនជាងលោកប៉ុន្មាន ក៏មានតែសេចក្តីចាញ់គំនិតលោកជាប្រាកដ ។ គុយកែឆ្លើយថា ដែលលោកលើកដំកើងលីប៉ោឲ្យធ្វើធំនោះ ខ្ញុំបាទគិតឃើញថាលីប៉ោជាមនុស្សអាក្រក់មិនជាអ្នកស្គាល់គុណអ្នកទាំងពួង សព្វថ្ងៃនេះ លីប៉ោ

ព្រាហ្មណ៍នឹងគិតប្រទូស្តរ៉ាយដល់លោក តែថានៅមិនទាន់មានឱកាស ឧបមាដូចបន្លាមុតនៅក្នុងដើមទ្រូងលោក ឥឡូវអ៊ួនសៀវលើកទៅវាយកងស៊ុនបាន បើលោកនឹងលើកទ័ពទៅវាយយកស្រុកអ៊ួនសៀវនឹងបានដោយងាយ តែក្រែងលីប៉ោដឹងនឹងលើកទ័ពត្រឡប់មកវាយក្រុងហ៊ូគោវិញ ហេតុនេះសូមលោកលើកកងទ័ពទៅកំចាត់លីប៉ោ ដែលជាសត្រូវនៅទិសបូព៌ាឲ្យរាបទាបហើយ ទើបគួរទៅវាយយកស្រុកអ៊ួនសៀវតែម្តង ទាន់អ៊ួនសៀវមិនដឹងខ្លួន ។ បូឆ្វយលឺឃើញត្រូវក៏ឲ្យទៅប្រមូលសេនាទាហានត្រៀមទុកនឹងលើកទៅវាយយកស្រុកឈីជីវ ។

ស៊ុនហុកជំរាបបូឆ្វយថា ដែលលោកនឹងលើកទ័ពទៅនោះ សុំឲ្យមានសំបុត្រទៅប្រាប់ឡៅពីឲ្យដឹងមុន ឲ្យឡៅពីជួយគិតកំចាត់លីប៉ោឲ្យបាន បើមានសំបុត្រឡៅពីប្តឹងមកដល់លោកជាការមាំមួនប្រាកដហើយ សុំលោកលើកកងទ័ពចេញទៅ ។ បូឆ្វយលឺឃើញត្រូវ ក៏ធ្វើសំបុត្រតាមពាក្យស៊ុនហុកថា, ហើយឲ្យទាហានកាន់ទៅឲ្យឡៅពីឯក្រុងសៀវផាយ ហើយតែងព្រះតម្រាស់ព្រះចៅហៀនតេ តាំងឲ្យអ៊ួនសៀវជាចៅហ្វាយស្រុកគីជីវ នឹងស្រុកបេងជីវ ស្រុកអឺវជីវ ស្រុកសៀងជីវ ៣ តំបន់នេះ ឲ្យនៅក្នុងបង្គាប់បញ្ជាអ៊ួនសៀវទាំងអស់ ព្រោះអ៊ួនសៀវមានគុណបំណាច់ល្អក្នុងរាជការ ហើយធ្វើសំបុត្រ ១ ច្បាប់ទៀតជាពាក្យបូឆ្វយថា "ឲ្យអ៊ួនសៀវលើកទ័ពទៅវាយកងស៊ុនបានចុះ យើងនឹងលើកទ័ពមក

ជួយធ្វើការនោះ" លុះធ្វើសំបុត្ររួចហើយ ចូចូក៏ប្រើបំរើឲ្យគាត់ទៅឲ្យ អ៊ួនសៀរនៅស្រុកគីជីរ ។ អ៊ួនសៀរទទួលព្រះត្រាម្ចាស់នឹងសំបុត្រ ចូចូមើលដឹងសេចក្ដីហើយ ក៏មានចិត្តសោមនស្សត្រេកអរជាទីបំផុត ទើបរៀបចាត់ការប្រមូលសេនាទាហានបានច្រើន ហើយលើកកងទ័ពទៅវាយកងស៊ុនចានចៅហ្វាយស្រុកប៉ាក់ប៉េង ។

ឯលីប៉ោដែលធ្វើចៅហ្វាយស្រុកឈីជីរនោះ ក៏មានសេចក្ដីសុខក្សេមក្សាន្តសប្បាយទូលាយចិត្ត គិតតែរៀបតុះលៀងអាហារសេនាទាហានជារៀង ៗ ឯគាត់គុយនឹងគាត់តេងក៏ក្លែងចរចាសរសើរលីប៉ោថា មានបញ្ញាតាំងចិត្តថ្លើមក៏ដ្រះថ្លាកប់អានទាហានខ្វាំងការ នឹងបណ្ដាពស្ត្រូទូទៅជាច្រើន ៗ គាត់កុងបានឮគាត់គុយនឹងគាត់តេងក្លែងពោលលើកសរសើរលីប៉ោរៀង ៗ ក៏មានសេចក្ដីក្រោធខឹងជាខ្លាំង ៗ លុះនៅមកកងថ្ងៃ ១ នោះគាត់កុងនិយាយនឹងលីប៉ោថា ដែលគាត់គុយនឹងគាត់តេងនិយាយសរសើរលោកនោះ តែត្រឹមបបូរមាត់ក្រៅប៉ុណ្ណោះទេ ឯចិត្តគាត់គុយនឹងគាត់តេងតែងគិតរកឧបាយនឹងប្រទូសរ៉ាយដល់លោកជាដរាប លោកកុំគប្បីជឿស្ដាប់ពាក្យវាទាំងអពុកនឹងកូននោះឡើយ បើលោកចេះតែជឿវាហើយ អំណើះទៅមុខ លោកក៏នឹងមានទុក្ខភ័យអន្តរាយជាប្រាកដ សុំឲ្យលោករិះរកឲ្យហ្មត់ចត់កុំធ្វេសប្រហែស ៗ លីប៉ោឮដូច្នោះក៏ស្រែកគំហកឲ្យគាត់កុងថា ខ្ញុំឃើញថាយើងមានចិត្តអាណិត

ស្រឡាញ់គាត់គុយគាត់តែង បានជាខ្លួនឯងទាស់ចិត្តមកគិតឫស្យា ញុះញង់ឲ្យយើងត្រឡប់ធ្វើទោសមនុស្សទៀងត្រង់កុំឲ្យនៅបាន ។

គាត់កុងបានឮដូច្នោះ ក៏ក្រោកដើរចេញហើយដកដង្ហើមធំគិតថា "លីប៉ោនេះជាមនុស្សល្ងង់អាប់ឥតប្រាជ្ញា ខ្លួនអញយល់ការថាដោយត្រង់ ទៅជាខឹងថាអញអាក្រក់វិញ អំណើះទៅមុខគង់នឹងមានសេចក្ដីអន្តរាយ ដោយទាំងអញផង តែថាបើអញនឹងលះបង់ចោលលីប៉ោដើរទៅរកទីពឹងពំនាក់ទៀត ក៏នឹងមានសេចក្ដីគរហានិន្ទា" លុះយាត្រាទៅដល់គ្រឹះហា ក៏គិតវិតក្កជាទុក្ខយូរថ្ងៃ ។

ក្នុងថ្ងៃមួយនោះ គាត់កុងក៏នាំបក្សពួកប្រហែល ៤-៥ នាក់ជិះសេះទៅបរបាញ់សត្វក្នុងព្រៃជិតស្រុកសៀវផាយ ឃើញទាហានម្នាក់បំផាយសេះចេញពីស្រុកសៀវផាយទៅ គាត់កុងសង្ស័យក៏នាំបក្សពួកបំផាយសេះតាមស្ទាក់ពីមុខទាន់ ហើយសួរថា នរណាប្រើខ្លួនទៅណាមកណាត្រូវការអ្វី? ។ ទាហាននោះក៏ភ័យស្លុតចិត្តព្រោះចាំមុខបានថា គាត់កុងជាទាហានលីប៉ោ បំរើការនាំសំបុត្រនោះក៏ឆ្លើយប្រាប់មិនរួច ។ គាត់កុងក៏ព្រួតគ្នាចាប់យកខ្លួនបានទាំងសំបុត្រ ១ ច្បាប់នាំទៅជូនលីប៉ោ ។ ក៏ដណ្ដឹងសួរថា នរណាឲ្យសំបុត្រនេះមកឯងកាន់យកទៅណា? ។ ទាហាននោះខ្លាចមិនអាចនឹងលាក់ទុកបានក៏ឆ្លើយតាមត្រង់ថា មហា-ឧបរាជប្រើខ្ញុំបាទកាន់សំបុត្រទៅឲ្យឡេវពីឯស្រុកសៀវផាយ ឡេវពីតប

សំបុត្របឹងទៅមហាឧបរាជវិញ សេចក្ដីសំបុត្រនោះនិយាយដូចម្ដេចខ្ញុំបាទមិនដឹង ។ លីប៉ោក៏ហែកស្រោមសំបុត្រនោះចេញមើលឃើញសេចក្ដីថា ខ្ញុំបាទទៀតពីបានដឹងក្នុងសេចក្ដីសំបុត្រមហាឧបរាជដែលបញ្ជូនទៅឲ្យខ្ញុំបាទ ឲ្យជួយរិះគិតកំចាត់លីប៉ោចេញនោះ ខ្លួនខ្ញុំបាទនឹងធ្វើការនោះមិនទាន់បាន ព្រោះកំឡាំងទាហានតិចជាងលីប៉ោ បើមហាឧបរាជលើកទ័ពមកកាលណា សុំខ្ញុំបាទចេញជួយធ្វើការកំចាត់លីប៉ោចេញឲ្យបាន ។

លីប៉ោដឹងក្នុងសំបុត្រដូច្នោះក៏ថា អាចូចូនោះវាគិតនឹងធ្វើអញ ៗ មិនបានកោតខ្លាចរាសោះ ហើយបង្គាប់ឲ្យយកទាហានចូចូនោះទៅប្រហារជីវិតបង់ ។ លីប៉ោក៏ប្រើតាន់កុងនឹងប៉ុងប៉ាទៅបញ្ចុះបញ្ចូលស៊ុនក្វន ១ ងីទុន ១, អ៊ុនឡេ ១, សៀងហ៊ូ ១, ដែលជានាយទាហាននៅក្នុងថៃសាន យកមកជាកំឡាំងហើយឲ្យលើកទ័ពទៅវាយខាងទិសបូព៌ា រហូតដល់ស្រុកគុនជីវ ឲ្យកោស៊ុននឹងតៀវលៀវលើកទ័ពទៅវាយ ស្រុកសៀវផាយចាប់យកខ្លួនទៀតពីឲ្យបាន ឲ្យស៊ុនហៀននឹងស៊ុយសុកលើកទ័ពទៅទិសបស្ចិម វាយយកស្រុកឃីអេង ទាហានទាំង ៣ កងនោះក៏លើកទៅតាមបង្គាប់លីប៉ោ ។ ឯខ្លួនលីប៉ោ ក៏លើកទាហានជាក្បួនទ័ពធំទៅត្រៀមបម្រុងស្ទាប់ជំណឹងទ័ពទាំង ៣ កង បើថាកងណាទន់ថយនឹងសត្រូវក៏នឹងបានលើកជាទ័ពណ្ហូនទៅជួយ ។ (មានត)

# រឿងអារក្សថ្លែងរឿងខ្មោច

## លោក វ៉ាយ-ប៊ុក ក្រមការ

*ប្រែពីបារាំងមកជាខ្មែរ*

(តមក)

## រឿងទីម្ភៃ

អារក្សក្រាបបង្គំទូលថា: បពិត្រមហារាជ! មានព្រះមហាក្សត្រិយ៍មួយអង្គ ទ្រង់ព្រះនាម ពិបុលេសវារ (Bipuleshvar) សោយរាជសម្បត្តិនៅនគរពិសលបុរ: (Bisalpur នគរ ពន្លកឈើ) នៅទីនោះមាននាយពាណិជម្នាក់ឈ្មោះអាថទត្ត (Aarthdatt: អំណោយដ៏ថ្លៃថ្លា), គាត់បានរៀបវិវាហ៍មង្គលការបុត្រីឈ្មោះនាង អនង្គមញ្ជរី (Anangamanjari) ទៅអ្នកជំនួញម្នាក់ឈ្មោះ មុនី នៅនគរ កនវលបុរ: (Kanwalpur) ។

បន្តិចមក លោកមុនីនោះបានចេញចាកគេហដ្ឋាន ធ្វើដំណើរទៅតាមសមុទ្រ ដើម្បីធ្វើពាណិជ្ជកម្ម, នាងអនង្គមញ្ជរីនៅតែម្នាក់ឯង ៗ មានកាលមួយថ្ងៃ ក្នុងវស្សានរដូវនាងនៅលើរានហាលនៃគេហដ្ឋានបានក្រឡេកមើលទៅតាមផ្លូវ ឃើញព្រាហ្មណ៍យុវជនម្នាក់ឈ្មោះ កាមលករ (KâmalaKar) ។ ក្អែកអ្នកទាំងពីរបានជួបប្រទះគ្នាហើយ ក៏កើតមានតណ្ហាប្រាថ្នាជួបគ្នាទៅវិញទៅមក ។ លុះកន្លងមួយម៉ោងមក, ព្រាហ្មណ៍កំឡោះនោះ ដោយសេចក្ដីឃ្លាតនាងដែលខ្លួនស្នេហាអម្បាញ់មិញនេះ

ក៏ខំទៅសួរមិត្តម្នាក់ដើម្បីបំភ្លេចនូវសេចក្ដីស្នេហានេះ ៗ ចំណែកនាងអនង្គមញ្ជរីព្រួយពន់ពេក ព្រោះមិនឃើញព្រាហ្មណ៍កំឡោះ ទៅជាដួលសន្លប់គាំងបាត់ស្មារតី ៗ តែមានស្រីម្នាក់ជាមិត្តក៏មកដល់បានលើកនាងឡើង តែនាងអនង្គមញ្ជរីនៅតែមិនដឹងខ្លួន ៗ មិត្តនាងបានប្រោះទឹកកុឡាប, យកទឹកអប់មកឲ្យនាងហិត ៗ នាងអនង្គមញ្ជរីបានភ្ញាក់ស្មារតីឡើង ហើយក៏ដេរប្រទេចផ្ដាសាកាមថា "ឱកាម! អាទិទេពសិរៈបានធ្វើអ្នកឯងទៅជាផេះ (ក្នុងពេលដែលព្រះអាទិទេពសិរៈកំពុងបម្រើនធម៌, កាមមកធ្វើឲ្យចិត្តកន្លល់; ទ្រង់ព្រះក្រោធជាខ្លាំង, ព្រះអាទិទេពសិរៈក្រឡេកទៅកាន់កាម កើតជាអណ្ដាតភ្លើងឆាបឆេះកាមទៅជាផេះ ព្រោះហេតុដូចនេះបានជាគេហៅរូបកាម.ជានាមធម៌) តែអ្នកឯងនៅមិនទាន់បោះបង់នូវចិត្តអកុសល ហើយអ្នកឯងធ្វើទុក្ខធ្វើបាបអ្នកសុចរិត ទុព្វលភាព ៗ ដល់នាងពោលពាក្យដូច្នេះ, នាងក៏ស្ងិតនៅស្ងៀម, យប់ក៏មកដល់, ព្រះចន្ទរះភ្លឺចាំងថែង ៗ នាងក៏ក្រឡេកទៅកាន់ព្រះចន្ទពោលថា: "ឱព្រះចន្ទ! ខ្ញុំបានឮគេថា នៅក្នុងខ្លួនអ្នកមានទឹកអម្រឹតដែលធ្វើឲ្យសត្វមិនស្លាប់ ហើយថាអ្នកឯងតែងបញ្ចេញទឹកអម្រឹតនោះជាមួយនឹងរស្មីអ្នក ៗ តែឥឡូវនេះ អ្នកឯងស្រោចមកលើខ្លួនខ្ញុំនូវទុសថពុល" ៗ រួចនាងក៏ពោលទៅកាន់ស្រីជាមិត្តរបស់នាងថា: "សូមនាងបីយកខ្ញុំចេញពីទីនេះ ព្រោះព្រះចន្ទបញ្ចេញភ្លើងឆាបឆេះ

ខ្លាចសត្វសព័ន្ធកាយខ្ញុំ" ។ ស្រីជាមិត្តបាននាំនាងយកទៅដាក់ក្នុងគេហដ្ឋានសម្រាប់សម្រាករបស់ខ្លួន ហើយសួរថា: "នាងពោលពាក្យបែបនេះមិនខ្មាសគេទេឬ? ។

នាងអនង្គមញ្ជរីពោលតបទៅវិញថា: "ខ្ញុំពោលទាំងប៉ុន្មាន ខ្ញុំដឹងទាំងអស់ តែតណ្ហាពាយខ្ញុំហើយធ្វើឲ្យខ្ញុំទៅជាស្ត្រីលង់មិនដឹងខ្លួនទៅវិញ ។ ខ្ញុំព្យាយាមរក្សាខន្តី តែភ្លើងដែលកើតឡើងមកពីការប្រាសព្រាត់ចាករបស់ជាទីស្រឡាញ់ពេញចិត្តឆេះរោលរាលចិត្តខ្ញុំហើយ គេហដ្ឋាននេះទៅជាដូចនុសថពុល"។ ។

ស្រីជាមិត្តតបទៅវិញថា: "ប្អូននាងស្ងិតនៅឲ្យស្ងៀម, ខ្ញុំនឹងដេញនូវសេចក្ដីទុក្ខចេញពីសន្ដាននាង" ។

នាងទាសីពោលដូចនេះក៏វិលត្រឡប់ទៅគេហដ្ឋានវិញ ។ នាងអនង្គមញ្ជរីក៏ត្រិះរិះក្នុងចិត្តថា: "អញនឹងលះបង់រូបនេះព្រោះសេចក្ដីស្នេហាបុរសនេះ, អញនឹងទៅចាប់បដិសន្ធិក្នុងភពខាងមុខ ហើយអញនឹងធ្វើសមន្ធកិច្ចជាមួយនឹងបុរសនេះឲ្យសប្បាយទាំងពីរនាក់" ។ ដល់នាងគិតយ៉ាងនេះ, នាងបានយកខ្សែចងព័ទ្ធជុំវិញក, នាងរៀបនឹងរំគនូវបំណងនោះ, ស្រាប់តែនាំងស្រីជាមិត្តមកដល់កន្ត្រាក់ខ្សែនោះចេញពីកនាង ហើយពោលថា: "គេអាចសម្រេចទៅតាមបំណងរបស់ខ្លួនបានលុះត្រាតែខ្លួននោះមានជីវិតរស់នៅ, មិនមែនលះបង់ជីវិតនោះទេ" ។

នាងអនង្គមញ្ជរីតបថា: "គួរតែស្លាប់ប្រសើរជាង, ខ្ញុំមិនអាចរងនូវទុក្ខលំបាកនេះបានឡើយ" ។

ស្ត្រីជាមិត្តតបទៅវិញថា: "ប្អូននាងសម្រាកចំនួន ១ ម៉ោងសិន, ចាំខ្ញុំនឹងនាំបុរសដែលនាងស្នេហានោះមកប្រគល់ជូននាង" ។

ស្ត្រីជាមិត្តពោលយ៉ាងនេះ, ហើយក៏ដើរទៅកាន់គេហដ្ឋានកាមលករ ហើយនាងពួនហើយក្រឡេកមើលទៅព្រាហ្មណ៍កំឡោះនោះ ។ កាមលករ កំពុងអង្គុយកើតទុក្ខពន់ប្រមាណ មានមិត្តម្នាក់បានយកនូវឱសថមកបិទនៅលើកាយគាត់ លាយខ្ទឹមបន្ទន់នឹងទឹកកុលាប ហើយយកស្លឹកចេកទន់បក់ឱ្យ ។ កាមលករដែលផ្ដើមក្នុងចិត្តពន់ពេកដោយភ្លើងរាគៈដុតពេលមនោទ្វារាវជ្ជនៈ ក្នុងការប្រាសព្រាត់ស្រីជាទីស្រឡាញ់របស់ខ្លួន ។ ព្រាហ្មណ៍កំឡោះនោះពោលថា: "ប្អូនអ្នកទៅយកឱសថពុលមកឱ្យខ្ញុំៗ ចង់ស្លាប់ឥឡូវនេះ ដើម្បីឱ្យផុតពីសេចក្ដីទុក្ខនេះ" ។ នាងទាសីបានឃើញស្ថានភាពនៃព្រាហ្មណ៍កំឡោះនោះយ៉ាងនេះ នាងគិតថា: "កាមនេះមានកម្លាំងខ្លាំង អាចធ្វើមនុស្សដែលម៉ឺងម៉ាត់មានប្រាជ្ញាឱ្យទៅជាមនុស្សគ្មានថាមភាពភ្លាមៗ បាន" ។ ដោយនាងបានគិតឃើញបែបនេះ, នាងក៏ស្រែកទៅកាន់កាមលករថា: "ឱកាមលករ! នាងអនង្គមញ្ជរីបានពោលថាឱ្យលោកអញ្ជើញទៅជួបនឹងនាង ដើម្បីនឹងឱ្យនាងមានជីវិតរស់នៅតទៅ" ។

កាមលករតបទៅនាងទាសីវិញថា: " នាងអនង្គមញ្ជរីជាប្អូនអាចឲ្យជីវិតមកខ្ញុំបាន", រួចព្រាហ្មណ៍ក៏ក្រោកឡើង, ដើរតាមនាងទាសីនោះទៅ ។ តែដល់ព្រាហ្មណ៍ទៅដល់គេហដ្ឋាននាងអនង្គមញ្ជរីៗ ក៏អនិច្ចកម្មក្នុងពេលនោះ ។ កាមលករក៏ប្រែកជួលសន្ទប់បាត់ស្មារតីហើយក៏ស្លាប់ក្នុងពេលនោះដែរ ។ ពេលបុព្វណ្ហសម័យ, ពួកជនក៏សែងអ្នកទាំងពីរនាក់ទៅថូបដ្ឋានហើយក៏បូជាទៅ ។ ក្នុងពេលកំពុងបូជាសព, លោកមុនីជាស្វាមីនាងអនង្គមញ្ជរីក៏វិលត្រឡប់មកពីប្រទេសក្រៅ បានដើរទៅកាន់ថូបដ្ឋាន ។ ដល់ពួមនុស្សយ៉ាំច្រើន នាយពាណិជមុនី ក៏ចូលទៅជិតទីបូជា ហើយក្រឡេកទៅឃើញភរិយារបស់គាត់កំពុងឆេះពេលពលជាមួយបុរសម្នាក់ ។ គាត់ក៏អស់សង្ឃឹម កើតទុក្ខពន់ប្រមាណ ស្រុះលោតទៅកណ្ដាលភ្លើងស្លាប់ក្នុងពេលនោះទៅ ។ ពួកអ្នកនគរបានត្រូដំណឹងបែបនេះ ពោលថា: "ភ្នែកយើងមិនដែលបានឃើញអច្ឆរិយភាពសម្បើមបែបនេះទេ, ត្រចៀកយើងក៏មិនដែលបានស្ដាប់រឿងពីពេះប្លែកបែបនេះឡើយ" ។

លុះដល់ថ្ងៃរឿងនេះចប់, អារក្សក៏ក្រាបទូលសួរព្រះមហាក្សត្រិយ៍ថា: "សូមទ្រង់ព្រះមេត្តាប្រោស! អ្នកទាំងពីរ តើអ្នកណាស្រឡាញ់នាងអនង្គមញ្ជរីជាងគេ?" ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលថា: "គឺស្វាមីនាង ស្រឡាញ់នាងជាងគេ" ។

អាក្សក្រាបបង្គំទូលសួរព្រះមហាក្សត្រិយ៍ថា: "សូមទ្រង់ព្រះមេត្តាប្រោស! ព្រោះហេតុអ្វី" ។ ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះរាជ-ឧង្ការថា: "ព្រោះឃើញកិរិយារបស់ខ្លួនស្លាប់ដោយសេចក្ដីស្នេហាចំពោះបុរសដទៃហើយ, ស្វាមីនាងនៅតែស៊ូប្ដូជាជីវិតដោយប្រោសបាកនូវចិត្តទោស: គឺស្វាមីនាងស្រឡាញ់នាងពិតប្រាកដ" ។

អាក្សបានស្ដាប់ព្រះរាជឧង្ការព្រះមហាក្សត្រិយ៍ ក៏វិលត្រឡប់ទៅព្យួរខ្លួនទីនរុក្ខជាតិសិរិស ។ ព្រះមហាក្សត្រិយ៍ក៏យកអាក្សលើលើព្រះអង្គនាំយកទៅ ។

ចប់ រឿងទី ២០ មានរឿងទី ២១ តទៅទៀត

## ទុក្ខកើតឡើង សុខរលត់

ផ្កាកូឡាបកប់ពាន់ផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់ តែបន្លានៃដើមកូឡាបតែមួយ បើមុត នាំឲ្យឈឺចាប់ បាត់ជុំក្លិនក្រអូបនៃផ្កាកូឡាបកប់ពាន់; សេចក្ដីទុក្ខតែមួយកើតឡើងកង្កណ្ដាលនៃសេចក្ដីសប្បាយរីករាយនៃអ្នកមានទ្រព្យច្រើន បណ្ដាលឲ្យបាត់សេចក្ដីសប្បាយរីករាយទាំងនោះ ។

យ. អ៊ី.

# រឿងចិញ្ចៀនទិព្យ

## អ្នកស្រីសារីយ៉ាន់ ប្រែពីបារាំងមកជាខ្មែរ

(តមក)

---

— ឱព្រះអនុជ! បងឃើញសេះបាមួយនៅផ្ទះបុរសម្នាក់, បងចង់បានសេះនោះណាស់ បងឲ្យមាស ១ ពាន់ឌីណាហើយ ម្ចាស់វានៅតែពុំព្រមលក់ឲ្យទៀត ហេតុដូច្នេះបានជាបងកើតទុក្ខ! ។

គ្រានោះ ព្រះអង្គម្ចាស់ អាលី-គូលេប៊ី ថយចូលទៅក្នុងបន្ទប់មួយ មួយស្របក់ហើយទ្រង់យាងចេញមកវិញ នាំទាំងស្ដេចគ្រិស្ដសាសនិក ដែលមានច្រវាក់ច្រាក់ចងព្រះហស្ដហើយមានខ្នោះព្រះសូរ៉ងមកផង ។ ព្រះអង្គម្ចាស់អាលី-គូលេប៊ីដើរតាមក្រោយ ដល់មកចំពោះព្រះភក្ត្របងទាំងពីរ ទ្រង់ក៏មានព្រះបន្ទូលថា: "ព្រះករុណា! សូមទ្រង់យកស្ដេចដែលចង់លើកទ័ពមកច្បាំងនឹងព្រះអង្គនេះចុះ" ។ លុះព្រះរាជាបានឃើញមនុស្សឈ្លើយមកហើយទ្រង់មានព្រះឧង្ការថា "ឯងនេះឬ ដែលចង់ធ្វើចម្បាំងនឹងអញ? តើឯងមិនដឹងថាអញនឹងវាយឯងទេឬអ្វី? យី! ឯងនេះល្ងង់ជាងសត្វត្ថទៅទៀត!" ។ កាលនោះ ស្ដេចគ្រិស្ដសាសនិកឆ្លើយថា: "ក្រាបទូលព្រះករុណាជាម្ចាស់ជីវិតលើត្បូង! ទូលព្រះបង្គំជាខ្ញុំពុំបានដឹងថា មានអារក្សនៅបំរើព្រះអង្គទេ" ។ បន្ទាប់ពីនោះគេយកអាហារនិងគ្រឿងផឹកមកថ្វាយ ។ ព្រះអង្គម្ចាស់ អាលី-គូលេប៊ី ទូល

បងបន្ទាប់ថា: "សេះបានៅក្នុងក្រោលសេះទ្រង់ឯណោះ" ។ ព្រះអគ្គម្ចាស់ទុបកដបាទព្ភដូច្នេះ ទ្រង់ស្ទុះចុះទៅមើលក្រោល ឃើញសេះទៅទីនោះមែន ទ្រង់មានព្រះទ័យសោមនស្សណាស់ ហើយត្រឡប់មកអង្គុយជាមួយគ្នាវិញ ព្រមទាំងស្តេចគ្រិស្តសាសនិកផង ។ គ្រានោះព្រះកជាបង់ស្រាយច្រវាក់ពីព្រះហស្តនឹងដោះខ្នោះពីព្រះស្ពូងនៃស្តេចជាប់ទោស ប៉ុន្តែស្រាយពុំបាន ។ ស្តេចជាប់ទោសមានព្រះបន្ទូលថា "គ្មាននរណាស្រាយចំណងនេះបានទេ ក្រៅអំពីអ្នកដែលបាននាំទូលព្រះបង្គំមក" ។ ស្តេចច្បងទាំងពីរព្រះអង្គនិយាយទៅព្រះអនុជថា "ចូរប្អូនស្រាយលែងទៅ' ។ អាលី-ត្លេលេបុ យកព្រះហស្តទៅដាក់លើច្រវាក់ដែក ៗ នោះ ក៏រលាចេញហើយខ្នោះនៅព្រះស្ពូងក៏របេះចេញ រួចក៏នាំរឿងយកមកនិយាយដដែលគ្នាលេង ។ ស្តេចគ្រិស្តសាសនិកទូលព្រះកជថា "ទូលព្រះបង្គំជាខ្ញុំចង់ត្រឡប់ទៅវិញ" ។ ព្រះកជាមានព្រះឧង្ការថា 'ចាំយើងឲ្យសេនាជូនដំណើរស្តេចចូលទៅព្រះនគរវិញ" ។

– ក្រាបទូលព្រះករុណាជាម្ចាស់ជីវិតលើត្បូង គេត្រូវដើរ ៣ ខែទើបដល់ទៅនគរទូលព្រះបង្គំជាខ្ញុំ ហើយបើសិនជាទូលព្រះបង្គំទៅបាត់តែ ៣ ថ្ងៃ គេនឹងលែងទទួលទូលព្រះបង្គំហើយ គេនឹងប្លន់ហើយកំទេចវាំងទូលព្រះបង្គំផង ។

ព្រះកជាត្រាស់សួរថា: "តើធ្វើដូចម្តេចទៅ?" ។ ស្តេចគ្រិស្តតបព្រះឧង្ការថា: "ត្រូវមុខងាររវាងអ្នកដែលនាំទូលព្រះបង្គំមក ទ្រង់នឹង

ជូនទូលព្រះបង្គំទៅវិញ ដ្បិតទូលព្រះបង្គំចុះខ្សន្យាណាន លើកកិត្តិយសជាស្តេចរបស់ទូលព្រះបង្គំ" ។ លុះបានទទួលសំបថហើយ ព្រះរាជាទ្រង់មានបន្ទូលទៅ អាលី-គ្មេលប៊ុំថា "ចូរប្អូននាំគេទៅវិញទៅ" ។ ព្រះអង្គម្ចាស់ក៏នាំស្តេចនោះទៅប្រគល់ឲ្យអារក្សមេម៉ូន ឲ្យនាំត្រឡប់ទៅព្រះនគរវិញ ។

ក្រោយមកស្តេចបងទាំងពីរអង្គគិតគ្នាថា: "អ្នកដែលអាចនាំស្តេចគ្រិស្តសាសនិកដែលនៅចម្ងាយផ្លូវដើរចំនួន ៣ ខែ ហើយនឹងនាំត្រឡប់ទៅវិញនេះ វានឹងអាចនាំយើងទៅគ្រប់តំបន់បាន តើយើងធ្វើយ៉ាងណាទៅ?" ។ ព្រះរាជាមានព្រះឱង្ការថា: "យើងគិតជប់លៀងទៀត យើងហៅអាលីមកផង ហើយយើងនឹងសុំក្រូចនៅស្រុក ការៀរ "Cha ir" នៅពេលដែលយើងកំពុងបរិភោគ, បើកាលណាវាចង់ក្រោក ត្រូវយើងកុំឲ្យវាក្រោកដើរទៅណា ហើយយើងចាំមើល តើវាធ្វើដូចម្តេច" ។

បងបន្ទាប់រៀបជប់លៀង ហើយអញ្ជើញព្រះអង្គម្ចាស់អាលី ។ លុះស្តេចទាំងបីព្រះអង្គបានសោយបន្តិចទៅ ស្តេចបងទាំងពីរសុំក្រូច ដ្បិតនៅក្រុងនេះគ្មានសោះ ។ ព្រះអង្គម្ចាស់អាលីឆ្លើយថា: "នឹងបានមួយរំពេច" ហើយក្រោកឈរឡើងប្រុងនឹងទៅយកក្រូចនោះមកថ្វាយ ប៉ុន្តែព្រះជេដ្ឋាទាំងពីរអង្គពុំព្រមឲ្យទ្រង់ទៅណា ។ ព្រះអង្គម្ចាស់អាលីក៏ហូតចិញ្ចៀនពីដៃដាក់ផ្ទាល់នឹងដី ស្រាប់តែមេម៉ូនបង្ហាញខ្លួនមកភ្លាម -

ទ្រង់គិបង្គាប់ឲ្យអារក្សបំរើទៅយកក្របួ ១ ថាសពីស្រុកកាអៀរ ។ អារក្ស កៀសខ្លួនបាត់ ១ សន្ទុះ ស្រាប់តែត្រឡប់មកវិញយកទាំងថាស ១ មានក្របួចំនួន ១០០ មកថ្វាយៈស្តេច ហើយទៅវិញបាត់ភ្លាម ។ ស្តេចច្បងទាំងពីរព្រះអង្គក៏ជាប់ទ្រង់គុណធម៌នៃចំពៀននោះ ប៉ុន្តែទ្រង់ទប់ព្រះអង្គធ្វើព្រងើយ ហើយសោយលេងសប្បាយតទៅទៀត ។

ព្រះរាជាមានព្រះបន្ទូលទៅព្រះអនុជថា: "បងសូមឲ្យប្អូនធ្វើឲ្យចេញរូបអារក្សដប់នាក់មក ហើយឲ្យមកបំរើយើងដោយកុំផ្លាស់ភេទឲ្យសោះ" ។ ព្រះអង្គម្ចាស់ អាលី-គោលេប៊ី ឆ្លើយតបព្រះរាជនុជ្ជាថា: "មិនអីទេ ទូលព្រះបង្គំថ្វាយដោយស្ម័គ្រ" ទើបទ្រង់ដាក់ចំពៀនដូចកាលសព្វដង ម៉ៃមួនមកដល់ភ្លាម ទ្រង់គិបង្គាប់តាមពាក្យដែលបងសុំ ។ ម៉ៃមួនទូលថា: "អម្ចាស់អើយ! អារក្សបំរើនៅក្រោយទ្រង់ស្រាប់" ។ ព្រះរាជានិងព្រះអនុជទាំងពីរបែរមើលក្រោយខ្នង ឃើញរូបអារក្សមួយៗ ដូចដើមត្នោត មានមាត់ធំហាក់ដូចជាចង្ក្រាន មានភ្នែកដូចភ្លើងចន្លុះពីរដើម ហើយរន្ធច្រមុះហាក់ដូចជាចង្រ្កានទឹកដែលធ្វើអំពីស្ពាន់ ។ លុះឃើញដូច្នោះព្រះជេដ្ឋាទាំងពីរព្រះអង្គក្រោកស្ទុះរត់ ហើយទ្រង់ស្រែកប្រាប់ព្រះអនុជថា: "ប្រាប់ឲ្យវាផ្លាស់ភេទទៅជាមនុស្សស្រួលបួលទៅ" ។ ពួកអារក្សបំរើផ្លាស់ភេទទៅជាមនុស្សបំរើយ៉ាងល្អដែលគេពុំដែលប្រទះ តាមព្រះរាជបញ្ជា ។ (មានទៀត)

# រឿងប៉ូល និងវីរស៊ីនី

## លោក ផើង-ជ្រើរ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

---

ការដែលដឹងថា វីរស៊ីនីត្រឡប់មកវិញជិតដល់ហើយ ធ្វើឲ្យអាប៉ូលមានកម្លាំងជាថ្មីទៀត ហើយនាំឲ្យវាខំយកចិត្តទុកដាក់ធ្វើការ ។ ហេតុតែកុសល វាកំពុងតែប្រឹងប្រែងខំធ្វើការ ស្រាប់តែមានដំណឹងល្អនាំឲ្យវារីករាយក្រៃពេក ត្រូវនឹងចំណង់របស់វា ។

ព្រឹកឡើងពេលថ្ងៃរះ គឺថ្ងៃ ២៤ ធ្នូ ឆ្នាំ ១៧៤៤ អាប៉ូលក្រោកពីដេក ក្រឡេកទៅឃើញទង់ជ័យសស្តុះដោតនៅលើកំពូលភ្នំឈ្មោះ ឡាដេគូវក ។ ទង់ជ័យដោតបែបនេះសម្រាប់ឲ្យដំណឹងថាមាននាវាមួយគេឃើញនៅក្នុងសមុទ្រ ។ អាប៉ូលស្ទុះរត់ទៅផ្សារក្រែងមានសំបុត្រវីរស៊ីនីផ្ញើមក ។ វានៅរង់ចាំរហូតដល់ ( មាត់ឡូ ) ម្នាក់ជិះកាណូតទៅសួរដំណឹងឲ្យដឹងតាមច្បាប់ ។ អ្នកនេះ ទាល់តែល្ងាចទើបមកដល់វិញ ។ គេជូនដំណឹងដល់លោកចៅហ្វាយថា នាវានោះឈ្មោះ សាំងសេរ៉ង់ តៃកុងឈ្មោះលោករូប៊ាំង ចតនៅចម្ងាយ ២២ គីឡូម៉ែត្រ នឹងចូលមកដល់កំពង់ពរល្វីនៅវេលាព្រឹកស្អែក ពេលបាយរួច បើមានខ្យល់ស្រួល ។ មាត់ឡូយកសំបុត្រទាំងប៉ុន្មានផ្ញើមកពីប្រទេសបារាំងទៅជូនលោកចៅហ្វាយ ។

មានសំបុត្រមួយមកនាងឡាគួរ, អាប៉ូលទទួលសំបុត្រនោះយកមកបើកដោយស្នេហាយ៉ាងខ្លាំង ហើយកាន់តែយកទៅផ្ទះមួយរំពេច ៗ លុះក្រឡេកឃើញក្រុមគ្រួសារវា អង្គុយរង់ចាំនៅលើដំបូលថ្មមួយ ឈ្មោះថ្មលាគ្នា អាប៉ូលលើកសំបុត្រពីចម្ងាយគ្រវីប្រាប់ រកនិយាយថាម៉េចមិនកើត ៗ ពួកមនុស្សទាំងឡាយមកប្រជុំគ្នាទៅផ្ទះនាងឡាគួរ ចាំស្តាប់គេមើលសំបុត្រ ៗ វីរស៊ីនីប្រាប់ម៉ែវាថា ម្ដាយមីងវាចិត្តអាក្រក់ពេក ចង់ឲ្យនាងមានប្ដី លុះនាងមិនព្រម គាត់គ្មានចែកទ្រព្យសម្បត្តិអ្វីសោះ ហើយបញ្ជូននាងមកក្នុងរដូវដែលមានខ្យល់ព្យុះ មិនចង់ឲ្យនាងមកដល់កោះបាំងវិញ ថានាងបានសុំគេមកជាមួយនឹងកាណូតដែរ តែលោកតៃកុងមិនព្រមបើកឲ្យ ព្រោះនៅឆ្ងាយពីកំពង់ពេកហើយសមុទ្រក៏ធំផងត្រង់កន្លែងនេះទោះបីស្ងប់ខ្យល់ក៏ដោយ ៗ

គ្រាន់តែមើលសំបុត្រហើយ ក្រុមគ្រួសារសប្បាយចិត្តលោតហក់កញ្ជងស្រែកថា: «វីរស៊ីនីមកដល់ហើយ ៗ» ម្ចាស់នឹងអ្នកបំរើឱបរឹតគ្នាទៅវិញទៅមកដោយសេចក្ដីត្រេកអរ ៗ នាងឡាគួរប្រាប់អាប៉ូលថា: «នែកូន! ចូរឯងទៅឲ្យដំណឹងដល់អ្នកជិតខាងថាវីរស៊ីនីមកហើយ» ៗ ឌូម៉ាំងដុតភ្លើងគប់ភ្លាម ហើយពីរនាក់នឹងអាប៉ូលដើរសំដៅផ្ទះខ្ញុំ (តាចាស់) ៗ

ប្រហែលម៉ោងដប់យប់ ខ្ញុំទើបនឹងលត់ចង្កៀង រៀបដេក ស្រាប់តែឃើញតាមចន្លោះរបងផ្ទះ នូវពន្លឺភ្លឺក្នុងព្រៃ ៗ មិនយូរប៉ុន្មាន

ខ្ញុំឮសូរមាត់អាប៉ូលហៅខ្ញុំ ។ ខ្ញុំក្រោកឡើងកំពុងស្លៀកពាក់ អាប៉ូលអរពេកបែបភ្លេចខ្លួន ហាត់គឃូស លោតឱបកខ្ញុំ ហើយឱនខ្សឹបប្រាប់ថា: “ទៅ! វីរ៍ស៊ីទីមកដល់ហើយ! ត្រូវយើងទៅឯកំពង់ផែ នាវាព្រឹកឡើងចូលមកដល់ហើយ” ។

យើងរៀបចំខ្លួនចេញទៅមួយរំពេច ។ វេលាកំពុងដើរឆ្លងព្រៃភ្នំវែងតាមផ្លូវបុំប្ញមុះសំដៅកំពង់ផែ យើងឮសូរអ្នកណាម្នាក់ដើរពីខាងក្រោយ ។ គឺពួកជាតិអ្នកស្រុកអាយម្នាក់ដើរបោះជំហានវែង ៗ ដើរបែបខំ ។ លុះគេមកទាន់យើង ខ្ញុំងាកសួរថា: មកពីណាទៅណា ដើរប្រញាប់អីម៉្លេះ? ។ គេឆ្លើយថា: “ខ្ញុំមកពីភូមិ ពូត-ឌរ, គេប្រើខ្ញុំមកឲ្យទៅកំពង់ផែ ជំរាបលោកចៅហ្វាយពីនាវាមួយដែលមកពីប្រទេសបារាំង ចតនៅខាងនាយកោះដំ, គេឮសូរបាញ់កាំភ្លើងហៅមនុស្សទៅជួយ ព្រោះសមុទ្រមិនល្អ” ។ មនុស្សនោះថាតែប៉ុណ្ណោះហើយក៏ខំស្រូតទៅមុខទៀតទៅ ។

ខ្ញុំប្រាប់ទៅអាប៉ូលថា “បើដូច្នោះ យើងត្រូវសំដៅទៅភូមិ ពូត-ឌរវិញ នៅចំពីមុខវីរ៍ស៊ីទីប្រហែលបីគីឡូម៉ែត្រទេ ពីនេះទៅ” ។ យើងក៏ដើរសំដៅទៅកោះប៉ែកទិសខាងជើងវិញ ។ ស្រាប់តែមានចេញចំហាយស្អុះយ៉ាងខ្លាំង ។ ព្រះចន្ទរះភ្លាឡើង គេឃើញវណ្ណមណ្ឌលបីខ្មៅនៅព័ទ្ធជុំវិញព្រះខែ ។ ដោយពន្លឺស្ទើនៃផ្លេកបន្ទោរ គេសំគាល់បានឃើញ.

មានពពកខ្មៅវែងល្វិតបីដួរយ៉ាងក្រាស មិនជាខ្ពស់ប៉ុន្មាន ដំរួតលើគ្នានៅពីលើចំកណ្ដាលកោះ ហើយសាត់មកពីកូនសមុទ្រយ៉ាងរហ័សថីជ្បិតមិនឃើញមានខ្យល់បន្តិចបន្តួចនៅលើដី ។ កំពុងដើរ យើងឮសូរផ្គរលាន់ តែដល់យើងយកត្រចៀកផ្ទៀងស្ដាប់យកមែនទែន យើងស្គាល់ជាក់ជាសូរគាំភ្លើងរំពងព្រៃ ។ សូរគាំភ្លើងឮល្វើយៗ ហើយមេឃថែមតាំងបំរុងនឹងមានខ្យល់ព្យុះ ការណ៍នេះនាំឲ្យខ្ញុំចង់ញាក់អីម៉្លេះទេ ? ខ្ញុំជឿជាក់ប្រាកដជាសូរគាំភ្លើងឲ្យសញ្ញាអំពីនាវាចង់លិច ។ កន្លះម៉ោងក្រោយមកបាត់ឮសូរគាំភ្លើង, រឿងសូត់ឈឹងនេះ ធ្វើឲ្យខ្ញុំរឹងរិតតែព្រួយបារម្ភច្រើនជាងឮសូរគាំភ្លើងលើកមុនទៅទៀត ។

យើងបបួលគ្នាចំស្រូតទៅមុខទៀត គ្មានហ៊ាននិយាយគ្នាឡើយ មិនហ៊ានថ្លែងសេចក្ដីព្រួយដល់គ្នានឹងគ្នាទេ ។ ប្រហែលម៉ោងដប់ពីរយប់ យើងបានដល់មាត់សមុទ្រកូនភូមិ ពូត-ឌរ បែកញើសស្រោក់ ។ រលកទឹកសមុទ្រមកពីនាយបែកសសំពោងក្លាតៗ ហូរលិចបាត់ថ្មរហូតមកប៉ះនឹងច្រាំងឮសូរគ្រូមៗ គួរឲ្យស្ញើបពន់ពេក ។ ពោះបីភ្រងងឹតសូន្យឈឹង គង់យើងសំគាល់ឃើញ ដោយសារពន្លឺអម្ពិលអម្ពែកសមុទ្រនូវទូកអកនេសាទដែលគេអូសបង្កៀងនៅនាខ្សាច់ ។

ឆ្ងាយពីយើងបន្តិច ឮជមាត់ព្រៃ គេឃើញភ្លើងមួយមានអ្នកស្រែកនៅព័ទ្ធជុំវិញ ។ យើងឈប់សម្រាកនៅទីនោះ រង់ចាំព្រឹកឡើង ។

យើងកំពុងតែអង្គុយនៅជិតភ្លើង អ្នកស្រុកម្នាក់និយាយថា: "ពីថ្ងៃរសៀល គេឃើញនាវាមួយនៅកណ្ដាលសមុទ្រ បើកសំដៅមកកោះតាមចរន្ដទឹកហូរ ដល់វេលាយប់គេមើលមិនឃើញព្រោះងងឹតពេក បានប្រហែលពីរម៉ោងក្រោយថ្ងៃលិច ឮសូរបាញ់កាំភ្លើងហៅគេឲ្យទៅជួយ តែទឹកសមុទ្រអាក្រក់ពេក គ្មាននរណាហ៊ានអុំទូកទៅជួយ បន្តិចទៀតឃើញដូចជាមានដុតចង្កៀង បើដូច្នេះ គេខ្លាចក្រែងនាវាមកជិតខាងពេក មិនហ៊ានបើកចន្លោះច្រាំងនឹងកោះធំ ហើយត្រឡប់យកកោះហ្នឹងជាជម្រុយវិញ ព្រោះនាវាទាំងប៉ុន្មានតែងបើកតាមច្រកហ្នឹងចូលមកកំពង់ផែល្វី បើប្រសិនឯចឹងមែនដូចគេថា គេក៏មិនហ៊ានទាយនោះ នាវាហ្នឹងសមនឹងមានគ្រោះថ្នាក់ធំ" ។ ម្នាក់ទៀតនិយាយឡើងថា: "គេបានឆ្លងត្រង់ច្រកជាចន្លោះកោះធំនឹងច្រាំងជាច្រើនដង បានវាស់ជំរៅមើលផង ឃើញថាត្រង់ហ្នឹងជ្រៅគួរសម នាវាអាចជែកនឹងរលកខ្យល់បាន ដូចជានៅឯកំពង់ផែធម្មតាដែរ" ។ គេនិយាយថែមទៀតថា "ខ្ញុំហ៊ានយកទ្រព្យសម្បត្តិទាំងអស់របស់ខ្ញុំទៅទុកក្នុងនាវានោះ ហើយត្រឡប់មកដេកយ៉ាងស្ងៀមនៅលើគោកឯណេះវិញ" ។ អ្នកទីបីមានវាចាថា "នាវាចូលក្នុងច្រកហ្នឹងមិនបានទេ គ្រាន់តែទូកតូចធម្មតាម៉េចគង់បើកមិនបាន" ។ គេអះអាងថាបានឃើញនាវាបោះយុថ្កាឆ្ងាយពីកោះធំ ហើយព្រឹកឡើងមានខ្យល់ នាវានោះនឹងចេញទៅក្រៅឬចូលមកផែបាន ។ (មានត)

# សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

បរិយាយពីដើមកំណើតមហោស្រព

## លោក ជាប-ពិន រៀបរៀង

---

អស់លោកទាំងឡាយ !

នៅប្រទេសកម្ពុជាយើង មហោស្រពព្រះរាជទ្រព្យ នឹងមហោស្រពអ្នកស្រុក គេហៅថា "ល្ខោន" តែនៅប្រទេសថៃ នឹងសៀម គេហៅថា "ល:ខន" ។

ពាក្យខ្មែរ ថា "ល្ខោន", នឹងពាក្យសៀម ថា "ល:ខន" សរសេរស្រដៀងគ្នា ប្លែកបន្តិចបន្តួចតែខ្យល់អាន, អក្សរបារាំងក៏ប្លែកតែខ្យល់អានដែរ ។

ពាក្យថា "ល្ខោន" ឬថា "ល:ខន" បើតម្រូវទៅតាមក្បាច់រាំតាំងពីកាលនៅយឺតៗ ឆ្ងាយៗ នៅឡើយ . ទំនងជាមកពីពាក្យជ្វា ថា "ឡាគូ" ដែលប្រែថា "ដើរ" ហើយដោយហេតុខ្មែរ-សៀម-លាវ-ភូមា ធ្លាប់ជាប់ទាក់ទងទំនៀមទម្លាប់គ្នាយ៉ាងជិតដិត ទើបក្បាច់មហោស្រពនៃប្រទេសទាំងនេះមានលំនាំស្រដៀងគ្នា ។ ប្រហែលជាមែន, ពីព្រោះពាក្យថា "ល្ខោន" ឬ "ល:ខន" នឹងពាក្យថា "ឡាគូ" មានឫសកែវជាមួយគ្នាតាំងពីព្រេងនាយមក ។

ល្ខោនខ្មែរ·ទីង លះខនសៀមមិនស្រដៀងគ្នាត្រឹមតែឈ្មោះប៉ុណ្ណោះទេ គឺរហូតទាំងក្បាច់ទាំងដំហាន ទាំងការជ្រើសរើសរឿងយកមកលេង ទាំងគ្រឿងភ្លេង ទាំងគ្រឿងតុបតែងសម្លៀកបំពាក់ ក៏ស្រដៀងគ្នាដែរ ។

យោបល់ដែលយល់ថា ល្ខោន ជាមហោស្រពមានឫសកែវឬដើមកំណើតជាមួយគ្នា នោះពិតជាត្រូវណាស់ ព្រោះមានដើមកំណើតមកពីឥណ្ឌាទាំងអស់ ដោយមានរឿងល្ខោនផ្សេងៗនិងក្បាច់រាំនានាជាច្រើនបែប ដែលគេត្រាទុកនៅក្នុងភារតនាដ្យសាស្ត្រ គឺក្បួនរបាំក្នុងរឿងមហាភារតយុទ្ធ និងការបម្រើនៃល្ខោនឥណ្ឌា ព្រមទាំងនានាប្រទេសដែលនៅក្រោមមហាអំណាចឥណ្ឌាជាសំអាង ។

តាំងពីបុរាណមក ប្រទេសទីមួយៗតែងបន្ថែមគំនិតប្លែកៗ ទៅលើដើមកំណើតនៃវត្ថុនីមួយៗ ហើយសន្សឹមៗកែប្រែខ្លះបន្តិចម្តងៗ ដើម្បីកំណត់គោលរបស់ខ្លួន ។

តាមទំនៀមស្រុក ល្ខោនខ្មែរកើតឡើងតាំងពីរជ្ជកាល ព្រះបាទជ័យវរ្ម័នទី ២ គឺព្រះកេតុមាលា ដែលមានព្រះនាមមួយយ៉ាងទៀតថា "បរមេស្វរៈ" ជាមហាក្សត្រសោយរាជ្យលើកដំបូងបង្អស់នៅអង្គរ ។

រឿងព្រេងដែលនិយាយពីព្រះរាជបុត្ររបស់ព្រះឥន្ទ្រ ជាធំជាងទេវតានៅឋានត្រៃត្រិង្ស ជារឿងទាក់ទងដោយសារតារមហោស្រពដែលនាំឲ្យរឿងនេះល្បីរន្ទឺខ្ទរទូទៅ ។ ហេតុដូច្នេះ បានជារឿងដែលទាក់

ទង់ដោយដើមកំណើតព្រះកេតុមាលា នឹងការកសាងអង្គរ ទៅជាការពិសោធន៍នៃមហាស្រព ទាំងជាស្នាដៃឫទ្ធិពលខ្មែរ បញ្ចេញឲ្យឃើញ ទី ១ នៅនឹងមហាស្រព, ទី ២ នៅនឹងគ្រឹះស្ថានសិល្បៈ ។

មានរឿងដំណាលថា: ព្រះឥន្ទ្រទ្រង់បើកទិព្វចក្ខុមកឃើញថាព្រះអគ្គមហេសីនៃព្រះមហាក្សត្រសោយរាជ្យនៅប្រទេសខ្មែរ គ្មានព្រះរាជបុត្រដល់មួយព្រះអង្គសោះ. ព្រះឥន្ទ្រមានព្រះទ័យសង្គ្រោះចង់បណ្តុះបណ្តាលឲ្យមានព្រះរាជបុត្រា តព្រះរាជសន្តតិវង្ស, ហេតុនេះទើបថ្ងៃ ១ ព្រះឥន្ទ្រទ្រង់ហោះទៅលើអាកាសវេហាស៍ នៅវេលាដែលព្រះរាជ-អគ្គមហេសីគង់នៅខាងក្រៅព្រះបរមរាជវាំង ។

ជនទាំងឡាយមើលពីដីទៅឃើញព្រះឥន្ទ្រដូចដុំរស្មីមួយ ក៏នាំគ្នាស្រែកថា: “ពន្លឺ ១ ធ្លាក់! ពន្លឺ ១ ធ្លាក់!” ហើយព្រះឥន្ទ្រដែលបញ្ចាំងរស្មីនោះ ក៏បង្អុរភ្លៀងផ្កាស្រោចស្រប់សព្វព្រះកាយនៃព្រះរាជអគ្គ-មហេសី ។ តាំងពីថ្ងៃនោះមក ព្រះរាជអគ្គមហេសីទ្រង់ព្រះគភ៌ ។ កាលទ្រង់ព្រះសូតព្រះរាជបុត្រ ១ ព្រះអង្គហើយ ព្រះនាងអគ្គមហេសីទ្រង់ព្រះរាជទានព្រះនាមថា “ព្រះកេតុមាលា” ប្រែថា “រស្មីបុប្ផា” តាមការណ៍ដែលចាប់ប្រដិសន្ធិដ៏អស្ចារ្យនោះ ។

នៅសម័យដដែលនោះ ស្រីទេពអប្សរម្នាក់បានចុះពីឋានសួគ៌មកបេះផ្កា ៦ ទងពីក្នុងសួនច្បាររបស់ចិនអ្នកក្រម្នាក់ ដោយឥតឲ្យនរណាឃើញសោះ ។

ព្រោះតែនាងទេពធីតាប្រព្រឹត្តបទល្មើសដូច្នោះ ព្រះឥន្ទ្រទ្រង់ដាក់ទណ្ឌកម្មឲ្យនាងចុះមកនៅឋានមនុស្សលោក ធ្វើជាភរិយាចិននោះអស់វេលា ៦ ឆ្នាំ ។

នាងទេពធីតាបានប្រសូតបុត្រមួយព្រះអង្គព្រះនាមថា "ព្រះពិស្ណុការ" តាំងពីកុមារមក ព្រះពិស្ណុការប៉ិនប្រសប់ខាងឯការចម្លាក់នឹងគំនូរ ។

កន្លងទៅ ៦ ឆ្នាំ នាងទេពអប្សរវិលត្រឡប់ទៅស្ថានសួគ៌វិញ, មុននឹងវិលត្រឡប់ទៅស្ថានលើ នាងដាក់ផ្កា ៦ ទងលើខ្នើយស្វាមីនាងជាសញ្ញាឲ្យដំណឹងដល់ស្វាមីពីរឿងដែលនាងត្រឡប់ទៅឋានសួគ៌វិញ ។ លុះព្រះពិស្ណុការមានជន្មាយុ ១០ ឆ្នាំ បានតាមស្វែងរកមាតាខ្លួន, កាលធ្វើដំណើរទៅជាច្រើនថ្ងៃ អស់កម្លាំងណាស់ ខោអាវដាចអស់ ប៉ុន្តែចេះតែអត់ទ្រាំ ដោយចង់ឃើញមាតា ។ មិនយូរប៉ុន្មាន ព្រះពិស្ណុការក៏បានជួបនឹងមាតាដូចបំណង ។

នាងទេពធីតា កាលជួបនឹងបុត្រហើយ ក៏នាំទៅថ្វាយព្រះឥន្ទ្រក្រាម, ព្រះឥន្ទ្រទ្រង់ចាត់ឲ្យពួកទេវតាបង្ហាត់ព្រះពិស្ណុការនូវវិជ្ជាសង់ផ្ទះ នឹងតុបតែងលំអផ្ទះ ។

កាលព្រះពិស្ណុការកំពុងរៀនវិជ្ជាសង់ផ្ទះអំពីពួកទេវតា, ព្រះឥន្ទ្រទ្រង់យាងទៅនាំព្រះកេតុមាលា ជាព្រះរាជបុត្រព្រះអង្គមកបង្ហាញឋានតាវត្តិង្ស ទ្រង់ត្រាស់បង្គាប់ឲ្យព្រះកេតុមាលាស្រង់ទឹក ១ ថ្ងៃ ៧ ដងពីព្រោះទឹកនោះមានគុណធម៌ឲ្យចម្រើនព្រះជន្ម ។

ដោយព្រះកេតុមាលាមានលក្ខណៈជាមនុស្ស ព្រះអង្គមិនអាចគង់នៅឋានតាវត្តិង្សបានយូរ, ព្រះឥន្ទ្រក៏ត្រាស់បង្គាប់ព្រះកេតុមាលា នឹងព្រះពិស្ណុការឲ្យយាងត្រឡប់មកឋានកណ្ដាលវិញ ហើយមានព្រះឧង្ការផ្ដាំព្រះពិស្ណុការឲ្យសង់ប្រាសាទតាមគំរូប្រាសាទ ដែលព្រះកេតុមាលាទ្រង់ទតឃើញនៅឋានតាវត្តិង្ស ហើយដែលទ្រង់សព្វព្រះរាជហឫទ័យផង ។

ដោយព្រះទ័យសុភាពរាបសារ ព្រះរាជបុត្រព្រះឥន្ទ្រសព្វព្រះរាជហឫទ័យត្រឹមប្រាសាទគោលគោប៉ុណ្ណោះ ដូច្នេះ កាលវិលត្រឡប់មកឋានកណ្ដាលវិញ ព្រះពិស្ណុការបានសង់ប្រាសាទមួយល្អវិចិត្រ ដូចប្រាសាទគោលគោនៃព្រះឥន្ទ្រសុទ្ធសាធ ។ ព្រះកេតុមាលាទ្រង់ពេញព្រះហឫទ័យនឹងប្រាសាទនោះពន់ពេក មិនតែប៉ុណ្ណោះបានត្រាស់បង្គាប់ព្រះពិស្ណុការឲ្យសង់ប្រាសាទមានរំលេចរចនាជាច្រើនទៀត ។ អាស្រ័យហេតុនេះហើយ ទើបកើតក្រុងអង្គរល្អប្លែក ។

ដល់វេលាធ្វើពិធីព្រះរាជាភិសេកព្រះរាជបុត្រា, ព្រះឥន្ទ្រយាងចុះមកស្ថានមនុស្សលោកម្ដងទៀត ។ នៅឱកាសនោះ ព្រះអង្គទ្រង់ព្រះរាជទានព្រះបរមនាមទី ២ ដល់ព្រះកេតុមាលា ហើយឲ្យហៅនគរនោះជាកម្ពុជាជាប់ដល់សព្វថ្ងៃនេះ ។ ព្រះឥន្ទ្របង្រៀនវិជ្ជាផ្សេងៗ សម្រាប់គ្រប់គ្រងនគរនឹងព្រះរាជទានព្រះខាន់រាជ្យ ដែលធ្វើឲ្យមាននគរចំណុះនគរខ្មែរជាច្រើន ទាំងផ្សាយជ័យជោគនៅពេញជុំវិញនគរខ្មែរ ។

ដោយសារព្រះឥន្ទ្រថាន យានមករៀបចំនគរខ្មែរសម័យអង្គរ ហើយពួកស្រីទេពអប្សរនឹងស្រីល្អានល្អៗ នៅឋានតាវត្តិង្សបានប្រគល់ល្បិចក្បាច់ល្ខោនគ្រប់បែបឲ្យមកខ្មែរ បានជាខ្មែរយើងប្រើសម្លៀកបំពាក់នឹងគ្រឿងប្រដាប់ស្រីល្ខោន តាមភាពស្រីទេពអប្សរនៅឋានសួគ៌តាំងពីសម័យអង្គរមក ដរាបដល់សព្វថ្ងៃនេះ ។

យើងស្ទះរឿងព្រេងត្រឹមនេះ ដើម្បីអធិប្បាយបញ្ចប់ដើមកំណើតល្ខោនខ្មែរថែមទៀត ឲ្យជាក់លាក់តទៅ ៖

រជ្ជកាលព្រះបាទជ័យវរ្ម័នទី ២ តាំងនៅក្នុង ឆ្នាំ ៨០២ ដល់ ៨៦៩ ។

ដូច្នេះ ល្ខោននោះជាល្ខោនចាស់ប្រហែលជាជិត ១១ សតវត្សមកហើយ, ទោះបីល្ខោនសម័យនោះមិនដូចល្ខោនសព្វថ្ងៃសុទ្ធសាធក្តី ក៏គេសន្និដ្ឋានបានថាលំនាំភាពល្ខោនសព្វថ្ងៃ ប្រហែលនឹងលំនាំឬភាពល្ខោនក្នុងសតវត្សទី ៩ ឯណោះ ដោយគេបានឃើញនៅប្រាសាទបាយ័នមានរូបចម្លាក់លំនាំក្បាច់រាំនឹងក្បាច់ល្ខោន ដែលស្ត្រីរបាំខ្មែរសព្វថ្ងៃយកដំរាប់តាមសុទ្ធសាធ ។ លំនាំក្បាច់ដែលគេតែងយកមករាំញឹកញយ គឺលំនាំក្បាច់កាន់ផ្កាៗ ភះពាំ ជើងពីរបោះកន្ត្រកឆ្ងាយពីគ្នាបន្តិច, ជើងមួយបត់លើកឡើងផុតពីដី, ដាក់ដៃម្ខាងសណ្តូកតាមភ្លៅ, ដៃម្ខាងទៀតបត់ត្រឹមកែងដៃ, បាតដៃទ្រផ្កាំរយោលឬផ្កាឈូកមួយទង, មេដៃនឹងចង្អុលដៃជិតភ្ជាប់គ្នា ម្រាមដៃ ៣ ទៀតពត់ងទន្ទាំ ឃ្លាតឆ្ងាយពីគ្នាបន្តិច ។

ក្បាច់មួយយ៉ាងដែលបង្ហាញឲ្យយើងឃើញញឹកញយ គឺក្បាច់ហោះ ជាក្បាច់គួរពិតពិលរមិលមើល, ប៉ុន្តែច្រើនតែមានលំនាំគ្គាំគ្គងខ្លះ ដោយបញ្ចេញការបត់បែនវិលវង់ហួសខ្នាតឃ្លាតចាកការពិត, តែទោះបីដូច្នោះក៏គេអាចកប់បញ្ចូលក្បាច់នោះទៅនឹងក្បាច់រចុំនានាដែលមានរបៀបហោះដូចគ្នា ជាក្បាច់មួយចម្លែក ល្អមើលជាងគេក្នុងចំណោមក្បាច់ល្ខោនខ្មែរ ។

រូបចម្លាក់នៅប្រាសាទបាយ័ននឹងក្បាច់ចម្លាក់ នៅលើប្រាសាទទាំងឡាយក្នុងអង្គរ មិនមែនធ្វើដំណាងក្បាច់ល្ខោនទាំងអស់ទេ, ក្បាច់ដែលធ្វើបង្ហាញឲ្យឃើញទាំងប៉ុន្មាន នោះក្លាយទៅជាក្បាច់ឯទៀតជាច្រើន, ប៉ុន្តែបើគេសំគាល់ក្បាច់ល្ខោន ដែលមានយកទៅធ្វើជារូបចម្លាក់នោះ គេអាចសន្មតថាការព្យាយាមក្នុងកិច្ចគោរពច្បាប់ដើមមិនបេះអស់ឡើយ ។

គ្រឿងអលង្ការ ដែលស្រីល្ខោនយកមកពាក់ គឺជាគ្រឿងតុបតែងរបស់ពួកស្រីទេពអប្សរ ប៉ុន្តែឯសម្លៀកបំពាក់មិនមែនរបស់ស្រីទេពអប្សរទេ លើកតែកំណាត់ដែលយកមកធ្វើជាសំពត់សំឡូយប៉ុណ្ណោះ ។

ឯគ្រឿងតុបតែងនេះ មិនមែនប្រើតាមទំនើងចិត្តអ្នកស្អាងឲ្យទេ គឺដល់ពេលក្រោយ ទើបគេបន្ថែមសម្លៀកបំពាក់បន្តិចម្តងៗ ឡើងទៀត ។ ត្រង់កន្លែងនេះគ្មានការអ្វីគួរឲ្យឆ្ងល់សោះ ពីព្រោះល្ខោនទាំងស្រុកខ្មែរ ទាំងស្រុកដទៃកើតឡើងតាំងពីអ្នកស្រុកនៅអាក្រាតនៅឡើយ ។

នៅប្រាសាទបាយ័ន គេឃើញមានរូបចម្លាក់មួយដំណាងជីវភាពស្ត្រីល្ខោនម្នាក់ គឺរបៀបងូតទឹក របៀបតុបតែងកាយ, របៀបពត់ខ្លួនទីង របៀបហាត់ គួរឲ្យពេញចិត្តចំពោះរូបចម្លាក់មួយនេះខ្លាំងណាស់ ដោយបានធ្វើឲ្យយើងដឹងថាស្ត្រីល្ខោនខ្មែរយើងមានជីវភាពហ្មត់ចត់ ដូចជាស្ត្រីល្ខោនក្រុមព្រះរាជទ្រព្យដែលតែងតែប្រកបជីវភាពនោះតរៀងមក ។

ទំនៀមទម្លាប់តែងប្រកាន់ទុកដោយម៉ឺនម៉ាត់នូវដើមកំណើត, ច្បាប់ជីវភាពសម្រាប់ស្ត្រីល្ខោន និងរបៀបរាំល្ខោន ។ តាមមតិរបស់អ្នកចេះដឹងជាតិថៃខ្លះថា នៅប្រទេសកម្ពុជានេះហើយ ដែលកាន់ទំនៀមដ៏បរិសុទ្ធ ។ គេបានដឹងថាប្រជាជនថៃ ក៏បានធ្វើឲ្យមហោស្រពរបស់គេបានចំរើនណាស់ដែរ ។ ឯមហោស្រពរបស់ខ្មែរយើង ពិតមែនតែយើងមិនបោះបង់ចោលសោះ ប៉ុន្តែយើងធ្វេសប្រហែសមិនសូវនិយមអស់រយៈពេលជាយូរណាស់ដែរ គឺក្នុងរវាងសតវត្សរ៍ទី ១៦ ដែលប្រទេសកម្ពុជាកំពុងឱនថយអានុភាព ហើយដល់សតវត្សរ៍ទី ១៧ ខ្មែរយើងទៅយករបៀបមហោស្រពរបស់ខ្លួនពីប្រទេសថៃមកវិញ ដែលគេកំពុងតែរៀបរយមហោស្រពនោះ តាមបំណងរបស់គេ ។ ប៉ុន្តែខ្មែរយើងមិនយកត្រឹមតែរបៀបល្ខោនមកវិញប៉ុណ្ណោះទេ គឺរហូតដល់ប្រែតាំងរឿងដែលថៃគេយកទៅលេងល្ខោនផង ។

នៅសម័យនោះ ក៏មានក្រុមល្ខោនប្រុស ស្រីក្នុងព្រះបរមរាជវាំងស្តេចនានា. ម្យ៉ាងទៀត ទោះសកដើងវត្តខ្លះៗ ដែលបានរក្សាទុក

ទូរសាស្ត្រវឿងកមរកេរ្តិ៍ បានប្រមូលកូនសិស្សលោកបង្កើតធ្វើជាក្រុមល្ខោនឡើង ដើម្បីជាការកំសាន្តខ្លួនឯង នឹងពួកកូនសិស្សលោក ។ អាស្រ័យហេតុនេះហើយ ទើបចំនៀមក្បាច់ល្ខោនមាននៅសល់ដោយអន្ទើៗ ។

ឯបព្វជិតនៅ សម័យនោះគឺការវិន័យតឹងតែងណាស់ សូម្បីតែការកំសាន្តបែបនេះ គឺបព្វជិតឥតបានទៅកំសន្តផងទេ ។ ម្ល៉ោះហើយគឺបណ្តាយឲ្យពុកម្តាយរបស់កូនសិស្សធ្វើតាមចិត្ត ។

គេមិនសូវជឿងច្បាស់ពីការផ្លាស់ប្តូរពាក្យប្រើក្នុងមហោស្រព, ល្ខោន ឬរបាំ នឹងរឿងល្ខោនទេ ។

នៅចុងបូព៌ាប្រទេស មហោស្រពនឹងរបាំផ្សេងៗ ដែលលាយឡំគ្នា គេមិនអាចនិយាយពីមួយពេលមួយបានឡើយ ។

ការពាក់ក្បាច់ ដុំបូងគ្រាន់តែជាការសំដែងមនោសញ្ចេតនារបស់មនុស្សប៉ុណ្ណោះទេ ដល់ក្រោយមកទើបបានគេកំរឿង ដែលបានលេងនៅក្នុងព្រះវិហារធំបំផុតរបស់សាសនា ។

សេរីភាពក្នុងការរាំនឹងក្នុងគំនិតផ្តើម ចួនកាលចំរើនពីការពិសិដ្ឋទៅជាមិនពិសិដ្ឋវិញក៏មាន, ប៉ុន្តែក្បាច់នៅដូចក្បាច់ដើមដដែល ព្រោះសៀវភៅពិសិដ្ឋបំបត់មហោស្រព នឹងល្ខោនឲ្យមានច្បាប់ដូចគ្នា ។

ពាក្យមហោស្រពនឹងល្ខោន ហៅជាពាក្យសំស្រ្កឹតតែមួយម៉ាត់ថា នាដ្យៈ ។

មុននឹងបង្កើតរឿងមហោស្រព នៅមានបរិយាយអំពីការមុិតព្រាយរបស់ល្ខោនដែលខ្មែរយើងយកតម្រាប់ពីប្រទេសសៀម ។ អធិប្បាយអំពីល័កេ ឬយីកេដែលប្រជាជនច្រើននិយមរាប់អាន ។ យីកេកើតមាននៅក្នុងប្រទេសកម្ពុជារវាងពាក់កណ្ដាលសតវត្សរ៍ប៉ុណ្ណោះ. ទាំងអាយ៉ៃឬអាប៉ៃ ក៏កើតក្នុងរវាងសតវត្សរ៍នោះដែរ គឺក្នុងឆ្នាំ ១៨៧៦ ក្នុងរជ្ជកាលព្រះបាទនរោត្តម ។

អាប៉ៃ គឺជាល្ខោនបរទេសមកពីស្រុកសៀម ដែលមានបែបដូចជាចម្រៀងឆ្លាះឆ្លងនៅប្រទេសលាវ ។

ដូនកាលអាប៉ៃនោះ គ្រាន់តែស្រីនឹងប្រុសម្នាក់អង្គុយទល់មុខគ្នាច្រៀងចោទឆ្លើយឆ្លាះឆ្លងទៅវិញទៅមក, ដូនកាលមានពួកស្រី-ប្រុសជាច្រើននាក់អង្គុយមួយបែកម្ខាងច្រៀងម្នាក់ម្ដងៗ ពីរឿងអ្វីមួយ ហើយទះដៃធ្វើជាចង្វាក់ភ្លេង ។

អាប៉ៃ បើកុំឲ្យតែបណ្ដាជនជ្វាយកដំរាប់តាមចម្រៀងឆ្លាះឆ្លង នៅប្រទេសលាវ ហើយយកមកក្លាយជាចម្រៀងសាសនា គឺជារបាំផ្សំអំពីយីកេជាន់ដើម ដែលមានដើមកំណើតពីជ្វា ទីងមុយស៊ុលម៉ង់ ។ ប៉ុន្តែយីកេជ្វាមិនមែនជារបាំកំសាន្ត ដូចជាអាប៉ៃនឹងយីកេនៅស្រុកសៀមទេ គឺជាចម្រៀងសាសនា ។

របៀបលេង គឺគេធ្វើជាពួកតាបសអង្គុយដកង់សូត្រធម៌តិចៗ ព្រមគ្នា មានតាបសម្នាក់និយាយរឿងម្នាក់ឯង កាត់ធម៌តាបសឯទៀតម្តងៗ ហើយមានពួកផ្កាដែលខ្វះកិច្ចគោរពពោលពាក្យក្រៅអំពីធម៌ បន្ទប់ពាក្យរឿងរបស់តាបសដែលកើតទៅជាការកំប្លែងចំអន់លេងពិតៗ ទៅវិញ ។ បណ្តាជនសៀមចូលចិត្តនឹងរបៀបកំប្លែងដូះបុះ ម្ល៉ោះហើយបើគេមើលយីកេគេគិតតែពីនាំគ្នាសើចមិនចេះស្រាក ។ ឯហេតុដែលយីកេផ្កាកើតទៅជាអាប៉េសៀម នោះជាការអោយរៀបរាប់ទេ ប៉ុន្តែការដែលធ្វើឲ្យយីកេចំរើនពីសៀមមកខ្មែរទៀត ជាការលំបាកណាស់ទៅវិញ ពីព្រោះយីកេដែលយើងធ្លាប់បានឃើញ គឺជាល្ខោនពិតៗ មានលេងជាច្រើននាក់មានសំលៀកបំពាក់ ចេញចូលកងឆាកកាក់ក្បាច់មានភ្លេងពិណពាទ្យអមផង មិនមែនច្រៀងឆ្លើយឆ្លងទេ ។ យីកេជាន់ក្រោយឃើញថាខុស ពីអាប៉េពីជាន់មុនឆ្ងាយណាស់ ។ ប៉ុន្តែយីកេឬអាប៉េមានគោលតែពីរដូចគ្នា គឺការកំប្លែងនឹងការស្និទ្ធស្នាល ។

ចម្រៀងកងអាប៉េ គ្មានពាក្យពីរោះពិសាថ្លៃថ្នូរទេ ពីព្រោះកាលដើមឡើយ អាប៉េកើតឡើងដោយសារតែពាក្យចំអន់ធម៌តាបសផ្កាលេងប៉ុណ្ណោះ ។

ចំណែកឯយីកេទៅជាល្ខោនមួយបែប ដែលគេយកដកប់ពីល្ខោនធម្មតានឹងលំនាំល្ខោនជាតិបរទេសនានា, ក្បាច់ល្ខោននោះប្រើសម្រាប់

កិរិយាកំផុតកំផែងលែបខាយ សម្លៀកបំពាក់កំប្រើជារបៀបកំផែងដែរ, ឯរឿងព្រេងប្រពូកប្របល់លាយឡំនឹងរឿងរបស់ជ្វា, ភូមា, មាឡាបារ, លាវ, ចិន ។ល។

គេជឿថា: ដែលយីកេលេងរបៀបនេះ គឺជាល្បែងថ្មីទើបនឹងកើតប្រហែលជា ២០០ ឆ្នាំប៉ុណ្ណោះ ។

បរិយាយពីដើមកំណើតមហោស្រពចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

### និគមនបទ:

ក្នុងលោកគេស្គាល់ខ្មែរយើងបាន
ដោយបានសិល្បៈអង្គរវត្ត
នឹងដោយមហោស្រពខ្មែរប្រាកដ
ជាច្រើនសតវត្សរ៍យ៉ាងចំណាន ។
ដូច្នេះ ខ្មែរថ្មីត្រូវរក្សា
មហោស្រពខេមរ នឹងគ្រឹះស្ថាន
សិល្បៈខ្មែរយើងពីបុរាណ
ឲ្យបានគង់វង្សរុងរឿងអើយ !

ប. ព.

សុន្ទរកថា

# លោកដុកទ័រគុណាបលៈបិយៈសេនៈម៉ាល៉ាលៈសេកេរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្លែងក្នុងសមាជសាកលលើកទី ២

នៃពុទ្ធសាសនានៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

## ពុទ្ធសាសនបណ្ឌិត្យ

(តមក)

---

ពួកពុទ្ធបរិស័ទត្រូវបេះបែលរករៀនខាងវិទ្យុទឹងកុន ដើម្បីជាប្រយោជន៍សំខាន់ដល់សាសនារបស់ខ្លួន ៗ ព្រោះហេតុដូចនេះ តាំងពីអតីតកាល, ពួកពុទ្ធបរិស័ទនីមួយៗ តែងឃោសនាផ្សាយព្រះបរមពុទ្ធោវាទនៅប្រទេសសព្វៗ ខ្លួន, ឥឡូវនេះពួកនេះ ត្រូវព្រួតដៃគ្នាព្យាយាមឃោសនាផ្សាយព្រះពុទ្ធសាសនា ដោយមធ្យោបាយរវាងជាតិ ៗ បានន័យថា ត្រូវតែយើងប្រឹងប្រែងឃោសនាផ្សាយព្រះធម៌ឲ្យបានឆ្ងាយទូលាយ ព្រមទាំងធ្វើសកម្មភាពឲ្យបានខ្លាំងក្លាជាងមុនទៅទៀត ៗ មធ្យោបាយក្នុងការឃោសនា ត្រូវយកទៅប្រើតាមវត្ថុបំណងនេះដោយគតិបណ្ឌិត ព្រមទាំងសន្តិប័យ ៗ ដូចជារឿងកំណោនដែលមានក្នុងផែនការណ៍អប់រំមនុស្ស ផ្សេងពីនេះបានបង្ហាញៈដោយជាក់លាក់នៅ

ផលដ៏ប្រសើរ ហើយត្រូវតែយកមកលេងដោយប្រយ័ត្នមាំមួន ព្រោះថាមានពុទ្ធសាសនិកជនជាច្រើនយល់ថា ពួកបុគ្គលិកពិសិដ្ឋមិនត្រូវឲ្យបុគ្គលសាមញ្ញ យកមកត្រដាងបង្ហាញនៅលើវិការដ្ឋាន ៗ បុគ្គលសាមញ្ញនេះមានសិទ្ធិតែមួយយ៉ាង គឺបង្ហាញនូវសេចក្ដីបុនប្រសប់របស់ខ្លួនក្នុងការរាំច្រៀងប៉ុណ្ណោះ ៗ នេះគឺជាន័យដែលត្រូវគោរពខានមិនបាន ៗ

## ក្រុមពុទ្ធសាសនា

ការអប់រំនូវធម្មទូត មានហេតុបច្ច័យទាក់ទងនឹងការឃោសនាជានិច្ច ៗ ត្រូវជ្រាបថា ព្រះពុទ្ធសាសនាជាសាសនាដែលបានចាត់ពួកបេសកធម្មទូតទៅផ្សាយក្នុងពិភពលោកមុនគេ ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់បានទេសនាទូន្មានប្រដៅយើងកល់គ្នាឲ្យនាំព្រះពុទ្ធោវាទ ទៅពន្យល់សត្វលោកគ្រប់ទិកន្លែង ដើម្បីជាសារៈប្រយោជន៍ដល់ទេវតានឹងមនុស្សទាំងឡាយ ៗ ពួកធម្មទូតមិនអាចបំពេញនូវសាសនកិច្ចឲ្យបានផលដ៏ល្អទេ បើខ្លួនមិនបានអប់រំជាមុនឲ្យមានវិជ្ជាគ្រប់គ្រាន់ ដើម្បីនឹងដំណើរការនោះឲ្យបានស្រួល, ឥឡូវនេះ សកម្មភាពនៃពួកធម្មទូត ស្ថិតនៅតែត្រឹមទ្វីបអាស៊ី បើយើងគិតជាមុនត្រង់វាតសកម្មភាពឲ្យបានឆ្ងាយទូលាយតទៅទៀត មានបញ្ហាសំខាន់ៗត្រូវយកមកវិនិច្ឆ័យដោយហ្មត់ចត់ គឺភោជនាហារ, សំលៀកបំពាក់ ដោយហេតុអាកាសធាតុមិនសភាព

ផ្សេងគ្នា ព្រមទាំងលែលកក្នុងការប្រព្រឹត្តប្រតិបត្តិ ជាយ៉ាងម៉ឺងម៉ាត់ ទៅតាមវិធានការនៃវិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាប្រដៅ ដូចជាការកាន់ប្រាក់ជាដើម ។ នេះត្រូវយល់ថាពួកធម្មទូតជាសមាជិក នៃព្រះសង្ឃ ។ បើតាមយោបល់របស់ខ្ញុំ មិនអាចមានវិចារណញ្ញាណ ណាទីងធ្វើដូចនេះបាន ហើយចំពោះខ្លួនខ្ញុំ សូមស្នើអំពីការស្ថាបនានូវ ក្រុមទូតជាថ្មីដែលមិនត្រូវប្រតិបត្តិតឹងរឹង ទៅតាមបំណងនៃសាសនា ដូចជាព្រះភិក្ខុ ខ្ញុំសូមស្នើរឿងនេះ សូមព្រះតេជព្រះគុណលោកអ្នក ជួយពិនិត្យ ។

ខ្ញុំអាចប្រគេន ឬជូនយោបល់ដូចគ្នា អំពីសកម្មភាពនៃមនុស្ស ជាតិ, សង្គមនិងការអប់រំខាងព្រះពុទ្ធសាសនា ។ នៅប្រទេសដែល កាន់ព្រះពុទ្ធសាសនាមហាយាន ដែលគេទុកឧត្តមគតិនៃព្រះពោធិសត្វ ជាទីតាំង, មិនមានអ្នកណាមួយអាចយល់ផ្ទុយនឹងការណ៍ដែលព្រះភិក្ខុ សាមណេរបានចូលទៅធ្វើសកម្មភាពបែបនេះ តែវិន័យខាងគណពុទ្ធ-សាសនាថេរវាទហាមមិនឲ្យធ្វើជាដាច់ខាត ។ ព្រោះហេតុដូចនេះ ក្នុងសម័យនេះបានជានៅប្រទេស ដែលនិយមកាន់ព្រះពុទ្ធសាសនាជា ច្រើន, ការបង្កើតនូវស្ថាប័ន សម្រាប់ជួយសង្គ្រោះដល់អ្នកក្រលំបាក ដូចជាគេហដ្ឋានសម្រាប់កូនកំព្រា, មន្ទីរពេទ្យបាលក្មេងក្រ, មនុស្ស ចាស់ជរា, មនុស្សពិការ, មនុស្សទុរ្ភិក្សហើយខ្វាក់ខ្វិន ធ្លាក់ទៅលើ

អ្នកដែលមិនបានកាន់ព្រះពុទ្ធសាសនា ។ មិនចាំបាច់ស្វែងរកនូវវិចារណញ្ញាណក្នុងគោលការណ៍ទេ តែត្រូវជ្រាបជាមុនថា ព្រះពុទ្ធសាសនាពីបឋមសម័យ អាចមានប្រពៃណីល្អ ប្រកបដោយមនុស្សធម៌ (សប្បុរសជាលក្ខណៈ) ។ យើងបានដឹងទាំងអស់គ្នាថា ព្រះសម្មាសម្ពុទ្ធទ្រង់បានបីបាច់ថែរក្សាភិក្ខុអាពាធមួយអង្គ ដែលមានកាយសុទ្ធតែរមាស់ ហើយទ្រង់បានត្រាស់ បង្គាប់ឲ្យៗ អាហារបរិភោគ ចំពោះមនុស្សឃ្លាន មុននឹងឲ្យមនុស្សនេះចូលមកស្តាប់ព្រះសទ្ធម្មវិសេសទេសនា; មែនហើយ, ហើយព្រះអង្គទ្រង់បានប្រគល់សេចក្តីថ្លៃថ្នូរឲ្យនាងពេស្យាម្នាក់ ដោយឲ្យអ្នកឯទៀត ទុកថាស្រីនោះជាមនុស្សជាតិ មិនមែនជាស្ត្រីមណ្ឌលថោកទាបទេ ។ តើយើងអាចមាននូវឧទាហរណ៍អ្វីប្រកបដោយអតិឧទាពជាងនេះទៅទៀតឬ?

អ្នកបានជ្រាបឬទេ ពីកាលព្រះអធិរាជអសោក បានស្ថាបនាមន្ទីរព្យាបាលនិងបដិសរណដ្ឋាន, មិនចំពោះតែមនុស្សទេ ថែមទាំងសត្វតិរច្ឆានផង ។ ប្រហែល ១ ៦០០ ឆ្នាំមកហើយ ព្រះមហាក្សត្រិយ៍ប្រទេសសីឡង់មួយអង្គ ទ្រង់បានតែងតាំងពិសេសនូវគ្រូពេទ្យ សំរាប់មើលថែរក្សាដំរី សេះ ក្រៅពីបដិសរណដ្ឋានដែលទ្រង់បានបង្កើតសំរាប់ពួកភិក្ខុពិការ, ពួកខ្វិននិងពួកអ្នកដំណើរតាមផ្លូវឆ្ងាយ ។

(មានត)

# ពិធីបុណ្យស្រោចទឹកព្រះសង្ឃបីអង្គ
# ជាមន្ត្រីសង្ឃ ក្នុងវត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប
# ព្រះអាចារ្យ ឈុយ-រ៉េង (ធម្មលិក្ខិតោ) ធម្មកោសលទោ
# គ្រូបង្រៀនសាលាបំពេញវិជ្ជាធម្មវិន័យ

*រៀបរៀង*

---

កាលពីថ្ងៃ ១២-១៣ ១៤ កើត ខែជេស្ឋ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៩៦ គឺថ្ងៃទី ៨ ៩ ១០ ខែមិថុនា គ.ស ១៩៥៣, ក្នុងវត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប មានពិធីបុណ្យមួយជាមហោឡារិក គឺបុណ្យសម្ពោធទទួលសញ្ញាប័ត្រ ស្រោចទឹកព្រះគ្រូបាសាទវង្ស កែ-អឿន (វិរិយប្បញ្ញោ) ដែលឡើងទីជាអនុគណ, លោកគ្រូ សែម-ពៅន (ធម្មជោតគ្គោ) ដែលឡើងទីជាចៅអធិការ នឹងលោកគ្រូ ឈឹន ញ៉ូង (បញ្ញាសិរី) ដែលឡើងទីជាអនុលេខាធិការនៃអនុគណ ។ ឯពិធីបុណ្យនោះដូចមាននៈសេចក្ដីខាងក្រោមនេះ :

## ក្លោងទ្វារធំខាងមុខវត្ត

នៅក្លោងទ្វារធំ មានតាក់តែងដោយអំពូលភ្លើងអគ្គិសនិធំ-តូចជាច្រើន នឹងដោតទង់ជាតិទង់សាសនា, នៅចំកណ្ដាលក្លោងទ្វារមានចារឹកអក្សរដោយផ្កាំងសំពត់ថា "បុណ្យស្រោចទឹកព្រះគ្រូអនុគណ នឹង

ហៅអធិការ" ។ បន្ទាប់អំពីក្លោងទ្វារមក មានបង់ទង់ជាតិខ្មែរវែងតាមសងខាងផ្លូវ នៅតាមសសរមួយៗ បង់ទង់ជាតិទង់សាសនាធំៗ ដរាបដល់ទីមុខព្រះវិហារ ។

## ទីមុខព្រះវិហារ

នៅទីមុខព្រះវិហារ មានរៀបគ្រឿងសក្ការបូជាថ្វាយចំពោះព្រះរតនត្រ័យ នឹងបង់ទង់ជាតិទង់សាសនា រំយោលផ្កាក្រដាសគ្រប់ពណ៌ ដាក់អំពូលភ្លើងធំ-តូចវែងខ្លីបញ្ចេញរស្មីភ្លឺខ្លោលកងវេលាយប់ ។ នៅមុខទ្វារធំព្រះវិហារសងខាង មានរៀបគ្រឿងតាំងតុដំកល់ព្រះពុទ្ធរូបកញ្ចក់ធំពីរលើតុនោះ នឹងគ្រឿងសក្ការៈផ្សេងៗ ។ នៅចំកណ្តាលទីក្រាលកន្ទេលចៀមចំព្រែព្រំ នឹងកៅអីជាជួរៗ, ផ្នែកខាងត្បូង សម្រាប់ទទួលបដិសណ្ឋារៈចំពោះព្រះករុណាជាម្ចាស់ជីវិត ស្តេចយាងទៅជាព្រះពជាធិបតី នឹងឥស្សរជនជាច្រើនដែលហែហមព្រះអង្គទៅ, ផ្នែកខាងជើង សម្រាប់ព្រះសង្ឃដែលមានសមណស័ក្តិ មានព្រះតេជព្រះគុណព្រះមុនីកោសលមេគណខេត្តបាត់ដំបងជាដើម នឹងភិក្ខុដែលត្រូវទទួលសមណស័ក្តិថ្មី ។ នៅត្រង់ចន្លោះកណ្តាលមានតុមួយក្រាលកម្រាលដ៏ស្អាត ដាក់តោកដាំខ្យងពីរជាន់ របនាដោយផ្កាស្រស់ៗ ចំរុះពណ៌ផ្សេងៗ ដំកល់សញ្ញាប័ត្រ ។ នៅចំកណ្តាលទ្វារធំព្រះវិហារ មានតុតូចមួយក្រាលកម្រាលដ៏ស្អាត ដំកល់តោកដាំខ្យងមួយ របនាដោយផ្កាស្រស់ៗ

បិទទៀន ៥ ធូប ៥ ជាគ្រឿងសក្ការបូជា សម្រាប់ព្រះករុណាជាម្ចាស់ជីវិតបូជានមស្ការព្រះរតនត្រ័យ, នៅខាងៗ ក្រាលកន្ទេលសម្រាប់ពុទ្ធបរិស័ទ ។

## បារាំនៅខាងមុខព្រះវិហារ

នៅខាងមុខព្រះវិហារមានធ្វើបារាំ ១ ខ្នង បណ្ដោយ ៦ ម៉ែត្រ ទទឹង ៤ ម៉ែត្រ កំពស់ ៥ ម៉ែត្រ ខាងលើពាសដោយសំពត់ឆ្នូត នៅសសរទីមួយៗ សុទ្ធតែស្រោបដោយស្លឹកដៃក្រមនិងកម្រងផ្កាឈើស្លឹកដៃក្រមស្លឹកច័ន្ទន៍ បង់ព័ទ្ធខាត់ខ្វែងជាក្រឡាសំណាញ់ និងផ្កាយោលផ្កាក្រដាសជាច្រើន, នៅខាងលើជុំវិញបារាំ ពាយសំពត់វែបសណ្ឋានទង់ជាតិសំយុងចុះមក, នៅក្រោមសំពត់វែបនោះពាយខ្សែភ្លើងអគ្គិសនីមានអំពូលគ្រប់ពណ៌ជាច្រើនព័ទ្ធជុំវិញ ។ នៅកណ្ដាលបារាំនោះមានធ្វើបុស្បុក ១ កំពស់ ៥ ម៉ែត្រ ទំហំ ១ ម៉ែត្រកន្លះជុំវិញ សម្រាប់ស្រោបទឹកអនុគណ-ចៅអធិការ-អនុលេខាធិការថ្មី ។ បុស្បុកនោះប្រដាប់របនា-វិចិត្រដោយផ្កាឈើស្រស់និងអំពូលភ្លើងតូចៗ បញ្ចេញរស្មីខៀវ-លឿង-ក្រហម-ស ។ នៅថ្នាក់កណ្ដាលនិងថ្នាក់ក្រោមរៀបដើមផ្កាឈើជុំវិញ, ថ្នាក់កណ្ដាលខាងមុខសងខាង ដម្កល់ពាងនាគពីរសម្រាប់ដាក់ទឹកមន្តប្រោះព្រំ, នៅមុខសងខាងបុស្បុក មានតុតូចពីរតាំងគ្រឿងសក្ការៈ, ត្រង់កណ្ដាល មានជណ្ដើររូបនាគកាំបី សម្រាប់ឡើងទៅលើបុស្បុក ។

# កម្មវិធី

## ថ្ងៃទី ១ គឺថ្ងៃទី ៨ ខែមិថុនា ព.ស. ២៤៩៦

ម៉ោង ៨ យប់និមន្តព្រះសង្ឃចំរើនព្រះពុទ្ធមន្ត និងនិមន្តព្រះតេជព្រះគុណ ព្រះមុនីកោសល មេគណរត្តពោធិផល ខេត្តបាត់ដំបង សំដែងធម្មទេសនាលើបុស្បុក ។

ម៉ោង ១១ បំបួសនាគ ។

## ថ្ងៃទី ២ គឺថ្ងៃទី ៩ ខែមិថុនា ព.ស. ២៤៩៦

ម៉ោង ៩ កន្លះព្រឹក ព្រះសង្ឃទាំងឡាយ មានព្រះតេជព្រះគុណមុនីកោសលជាប្រធាននឹងពុទ្ធបរិស័ទជាច្រើន ជួបជុំរង់ចាំទទួលព្រះប្រិយមហាក្សត្រិយ៍ និងឥស្សរជនដែលហែហមព្រះអង្គ និងមន្ត្រីក្នុងខេត្ត ។

ម៉ោង ១០ កន្លះ ព្រះករុណាជាម្ចាស់ជីវិតស្ដេចយាងទៅដល់ ក្រុមភ្លេងលេងភ្លេងនគររាជថ្វាយ, លុះស្ដេចយាងដល់ហើយ គង់ប្រថាប់លើព្រះទីនាំងកៅអី ។ បន្ទាប់ពីនោះមក ឧបាសកទៀម រឿន បិទទៀនដំកល់លើជើងពានកែវ យកទៅថ្វាយព្រះករុណា ។ ទ្រង់ប្រទានព្រះអគ្គី ហើយឧបាសកនោះទទួលយកទៅបូជាព្រះរតនត្រ័យ ។ តមកព្រះតេជព្រះគុណព្រះមុនីកោសលផ្ដើមសូត្រជយន្តោថ្វាយព្រះពរជយមង្គល ព្រះសង្ឃទាំងអស់ក៏ទទួលសូត្រទំហឹងអឺងកងឡើង ។ លុះចប់ហើយ

ព្រះតេជព្រះគុណព្រះមុនីកោសល ថ្លែងសេចក្តី ទទួលអំណរព្រះប្រិយ-មហាក្សត្រ ដែលស្តេចឈ្លៀតយាងមកជាព្រះរាជាធិបតី ហើយសូត្រអានសញ្ញាប័ត្រទាំង ៣ នោះ រួចព្រះករុណាប្រគេនសញ្ញាប័ត្រដល់ភិក្ខុទាំង ៣ រូប ។ តពីនោះមកព្រះអាចារ្យ កែវ អ៊ុំ ថ្លែងសេចក្តីទទួលអំណរថ្វាយព្រះរាជកុសលនិងអធិប្បាយអំពីកិច្ចផ្សេងៗទៀត ចប់ហើយព្រះគ្រូអនុគណថ្មី លោកគ្រូចៅអធិការថ្មី និងលោកគ្រូអនុលេខាធិការថ្មីឡើងកាន់បុស្បក ព្រះករុណាឡើងតាមក្រោយ ទើបឧបាសកគុយ-ប្រោញយកផ្តិលប្រាក់ដាក់សុគន្ធវារីថ្វាយព្រះករុណា ។ ទ្រង់ប្រោះសុគន្ធវារីនោះលើព្រះហស្តព្រះគ្រូអនុគណ-លោកគ្រូចៅអធិការ និងលោកគ្រូអនុលេខាធិការ ទ្រង់មានព្រះរាជឱង្ការប្រទានពរថា: "សូមឲ្យព្រះករុណា ទាំង ៣ អង្គបានប្រកបដោយសេចក្តីសុខ និងសេចក្តីចំរើនអស់កាលជាយូរអង្វែង" ។ ព្រះសង្ឃទាំងអស់សូត្រជយន្តោប្រគេនពរដល់ព្រះគ្រូអនុគណ-ចៅអធិការ និងអនុលេខាធិការ ។ បន្ទាប់មកព្រះតេជព្រះគុណព្រះមុនីកោសលឡើងកាន់បុស្បក ប្រោះសុគន្ធវារីម្តងទៀតដល់ព្រះគ្រូអនុគណ-ចៅអធិការ-អនុលេខាធិការ ។ រួចកិច្ចនេះសព្វគ្រប់ហើយ ព្រះករុណាស្តេចយាងត្រឡប់វិញ ។

ម៉ោង ១២ ប្រគេនភត្តាហារចំពោះព្រះសង្ឃ ។

ម៉ោង ៨ យប់ និមន្តព្រះសង្ឃចំរើនព្រះបរិត្ត រួចនិមន្តព្រះអាចារ្យ កែវ អ៊ុំ សំដែងធម៌ទេសនា ។

ថ្ងៃទី៣ គឺថ្ងៃទី ១០ ខែមិថុនា ព.ស. ២៤៩៦

ម៉ោង ១១ និមន្តព្រះសង្ឃសូត្រពាហុំទេវាជូន ហើយប្រគេនភត្តាហារ,

ម៉ោង ៨ យប់និមន្តព្រះវិន័យធរ ឯក-ញឹម សំដែងធម៌ទេសនា សម្រេចកិច្ចបុណ្យតែប៉ុណ្ណេះ ។

វត្តព្រះព្រហ្មរតន៍ក្នុងពេលនេះមានភ័ព្វគាប់ប្រសើរជាងពេលណា ៗ ទៅទៀត ព្រោះក្នុងពិធីបុណ្យណា ៗ មិនដែលបានព្រះករុណាជាម្ចាស់ជីវិតស្ដេចយាងមកជាព្រះរាជាធិបតីទេ ទើបតែក្នុងពិធីបុណ្យនេះ បានស្ដេចទ្រង់យាងមកជាសិរីសួស្ដីជ័យមង្គល ។

យើងខ្ញុំព្រះអង្គជាក្រុមពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ មានសេចក្ដីសោមនស្សចំពោះព្រះគុណាតិរេកជាយ៉ាងក្រៃលែង ទឹងរកវត្ថុអ្វីក្នុងលោកប្រៀបផ្ទឹមស្មើពុំបាន ។

យើងខ្ញុំព្រះអង្គសូមឧទ្ទិសកុសលបុញ្ញាភិសង្ខក្នុងពេលនេះ ថ្វាយចំពោះព្រះបរមមហាក្សត្រ សូមឲ្យទ្រង់ស្ថិតក្នុងព្រះសិរីរាជសម្បត្តិខាត់កយាជាសុខសាន្ត សម្រាន្តក្នុងព្រះកាយពល ទាំងមានព្រះជន្មាយុយឺនយូរ ព្រមទាំងមានព្រះតេជានុភាពពេញបរិបូណ៌ អស់កាលជាយូរអង្វែងទៅហោង ។